## ព័ត៌មានសំខាន់ៗខាងក្នុង...

"ប៉ូលិសអាកាដេមិ" បញ្ចេញនាយប៉ូលិសជំនាន់ទី២១

សូមអាននៅទំព័រទី ១២



សមាជិកក្រុមប្រឹក្សាក្រុងឡូវែលពិចារណាពីការហាមឃាត់ការចិញ្ចឹមឆ្កែ

សូមអាននៅទំព័រទី ១៣



ប្រវត្តិនៃព្រះរាជពិធីបុណ្យអុំទូក អកអំបុក បណ្តែតប្រទីប....

សូមអាននៅទំព័រទី ១០



សម្ភាសន៍ជាមួយព្រះអង្គម្ចាស់ធម្មិកោ

សូមអាននៅទំព័រទី ០៤



សារព័ត៌មាន ខ្មែរផុស ស.រ.អា
KhmerPost USA
FREE BIWEEKLY CAMBODIAN ENGLISH NEWSPAPER SINCE 2007
978-677-7163 • VISIT KHMERPOST.US

7 Video
ទទួលផ្ញើអីវ៉ាន់ ទៅវិញទៅមកស្រុកខ្មែរ
- ផ្ញើ១ផោន តម្លៃ ១០ដុល្លារ
- ធនា បើសិន បាត់ ឬបាក់បែក
- ដឹកជញ្ជូនដល់ផ្ទះ
ទំនាក់ទំនង ៖ Mr. យុទ្ធ (978) 876-1985
660 Middlesex St., Lowell, MA 01851
(978)710-6356

# ដំណើរ១២ថ្ងៃរបស់ប្រធានាធិបតីត្រមទៅកាន់អាស៊ី

**ខ្មែរផុសស.រ.អា**

USA: លោកប្រធានាធិបតី ឌុណល ត្រម នឹងស្ត្រីទី១នៃសហរដ្ឋអាមេរិកម៉ាឡេនីញ៉ា ត្រម បានចាកចេញដំណើរតាមយន្តហោះ"Air Force 1" ពីកោះហាវៃ កាលពីថ្ងៃសុក្រទី៤ វិច្ឆិការនេះ សំដៅទៅប្រទេសជប៉ុន ដែលជាដំណាក់ការទី១នៃដំណើរ១២ថ្ងៃ ដើម្បីទៅពង្រឹងស្ថានការយុទ្ធសាស្ត្រតំបន់ដែលកំពុងតែរំជើបរំជួលជាខ្លាំងនៅអាស៊ី។ ក្នុងដំណើរនេះលោកមានគម្រោងនឹងចុះចត បន្ទាប់ពី១-ជប៉ុន គឺទៅ២-កូរ៉េខាងត្បូងទៅទី៣-ឡាណាងនៃប្រទេសវៀតណាម ទៅ៤-ហាណូយ ទៅ៥-ប្រទេសចិន ទៅ៦-ប្រទេសហ្វីលីពីនមុននឹងត្រឡប់មកស.រ.អាវិញ។

តើមានអ្វីខ្លះកំពុងតែកើតឡើងនៅអាស៊ីៈ

១-ប្រទេសជប៉ុន នឹង កូរ៉េខាងត្បូង ជាប្រទេស"ប្រជាធិបតេយ្យ-សេរី" គឺជាសម្ព័ន្ធមិត្តអាមេរិកដ៏រឹងមាំដែលមានស្ថានភាពសេដ្ឋកិច្ចរបស់ពួកគេ **តទៅទំព័រទី ០៨**



ប្រធានាធិបតី ត្រម ទៅដល់ជប៉ុន

# គណបក្សសង្គ្រោះជាតិចង់រំលាយខ្លួនឯង

**ថ្ងៃទី១វិច្ឆិកា២០១៧ - ដោយ ពិន សំខុន**



កឹម សុខា



សម រង្ស៊ី



ម៉ៅ មុន្នីវណ្ណ

សូមអាននៅទំព័រទី០៣

សារព័ត៌មាន ខ្មែរផុស ស.រ.អា
KhmerPost USA
Cambodian American Biweekly Newspaper
Connecting 10,000 Khmer-speaking households per Month with an average of 5 members per household. Free Newspaper copies are available in these cities:
Massachusetts:
- Lowell
- Lynn/Revere
Rhode Island:
- Providence
- Cranston
CELEBRATING 10 YEARS
Contact us for the Advertising Opportunity!
978-677-7163 | http:/khmerpost.us

# បានទទួលមួយ ឬទាំងពីរក្នុងចំណោមប័ណ្ណទាំងនេះ?

# ទទួលយកបន្ថែម។




ទទួលយកអត្ថប្រយោជន៍ច្រើនជាងអ្វីដែលអ្នកបច្ចុប្បន្នកំពុងទទួលបានពី Original Medicare និង MassHealth ជាមួយគម្រោង **UnitedHealthcare® Senior Care Options (HMO SNP)**។ វារួមបញ្ចូលគ្នានូវវេជ្ជបណ្ឌិតរបស់អ្នក មន្ទីពេទ្យ និងការគ្របដណ្តប់ឱសថមានវេជ្ជបញ្ជាគ្របទៅក្នុងគម្រោងមួយ គឺសម្រាប់ បុព្វលាភរ៉ាប់រងគម្រោង **$0**។**

## អត្ថប្រយោជន៍បន្ថែមអាចរួមមាន៖

**ឱសថមានវេជ្ជបញ្ជា**
រាប់ពាន់នៃឱសថអាចប្រើបាន។

**ការគ្របដណ្តប់លើទន្តសាស្ត្រ**
សហចំណាយ **$0** សម្រាប់ការដាក់ធ្មេញ និងក្រាសធ្មេញពាក់។

**ជំនួយលើមធ្យោបាយធ្វើដំណើរ**
សហចំណាយ **$0**សម្រាប់ការជិះទៅជួបវេជ្ជបណ្ឌិតតាមការណាត់។

**កាតាឡុកផលិតផលសុខភាព**
រហូតដល់ទៅ **$320** ក្នុងឥណទានប្រចាំឆ្នាំដើម្បីទិញ ផលិតផលសុខភាពពីកាតាឡុករបស់យើង។

**ទូរស័ព្ទមកថ្ងៃនេះដើម្បីចុះឈ្មោះ ឬទទួលបានចម្លើយទៅនឹងសំណួររបស់អ្នក។**



BOPHA PEOU
License # 2016784
**Contact # (978) 221-9970, TTY 711**
[8 a.m. – 8 p.m. local time, 7 days a week]

**UHCCommunityPlan.com/MA**

UnitedHealthcare
Community Plan

UnitedHealthcare SCO គឺជាគម្រោងថែទាំសុខភាពដែលមានការសម្របសម្រួលមួយ ដែលមានកិច្ចសន្យាជាមួយ Medicare និងជាប់កិច្ចសន្យាជាមួយកម្មវិធី Commonwealth of Massachusetts Medicaid ។ ការចុះឈ្មោះនៅក្នុងគម្រោងគឺផ្អែកទៅលើការបន្តកិច្ចសន្យាជាថ្មីរបស់គម្រោងជាមួយ Medicare ។ គម្រោងនេះគឺជាកម្មវិធីស្ម័គ្រចិត្ត ដែលអាចរកបានសម្រាប់អ្នកដែលមានវ័យចាប់ពី 65 ឆ្នាំឡើងទៅ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ MassHealth Standard និង Original Medicare ។ ប្រសិនបើលោកអ្នកមាន MassHealth Standard ប៉ុន្តែលោកអ្នកមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីទទួលបាន Original Medicare លោកអ្នកនៅតែមានសិទ្ធិចុះឈ្មោះក្នុងគម្រោង MassHealth Senior Care Option និងទទួលបានអត្ថប្រយោជន៍ MassHealth ទាំងអស់របស់លោកអ្នកតាមរយៈកម្មវិធី SCO របស់យើង។ ព័ត៌មាននេះគឺមិនមែនជាការពិពណ៌នាពេញលេញអំពីអត្ថប្រយោជន៍នោះទេ។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកគម្រោង។ ការកំណត់សហចំណាយ និងការដាក់កំហិតនានាអាចត្រូវអនុវត្ត។ អត្ថប្រយោជន៍ បុព្វលាភរ៉ាប់រង និង/ឬសហចំណាយ/សហធានារ៉ាប់រងអាចផ្លាស់ប្តូរនៅថ្ងៃទី 1 ខែមករានៃឆ្នាំនីមួយៗ។ បុព្វលាភរ៉ាប់រង សហចំណាយ សហធានារ៉ាប់រង និង ថ្លៃបង់ប្រចាំឆ្នាំមុនពេលធានារ៉ាប់រងបង់ឲ្យ អាចប្រែប្រួលតាមកម្រិតនៃជំនួយបន្ថែមដែលលោកអ្នកទទួលបាន។ សូមទាក់ទងមកគម្រោងសម្រាប់ព័ត៌មានលំអិតបន្ថែមទៀត។ អ្នកចុះឈ្មោះមិនតម្រូវឲ្យបង់ប្រាក់ពីហោប៉ៅឡើយ។

H2226_150915_093829 Accepted
UHCSCO_150915_093829
CST10056_ H2226-001

# គណបក្សសង្គ្រោះជាតិចង់រំលាយខ្លួនឯង

**ថ្ងៃទី១វិច្ឆិកា២០១៧ - ដោយ ពិន សំខុន**

ស្ថានភាពកំពុងច្របូកច្របល់ថា "គណបក្សសង្គ្រោះជាតិអាចនឹងចូលរួមបោះឆ្នោតបាន"នោះ ចេះតែកើនសំពាធសម្រាប់ "រំលាយគណបក្សសង្គ្រោះជាតិ"ដោយរដ្ឋាភិបាលខ្មែរជាលំដាប់, សេចក្តីសង្ឃឹមថា សហគមន៍អន្តរជាតិនឹងលូកដៃមក"ជួយស្តារស្ថានភាពនយោបាយយ៉ាប់យ៉ឺន" នេះក៏កាន់តែមានសង្ឃឹមខ្ពស់ឡើងដែរ, ស្រាប់តែព្រឹត្តិកាណ៍ចុងក្រោយបែរជាឮថា មានការប្រេះឆាជាទម្ងន់ក្នុងរង្វង់គណបក្សសង្គ្រោះជាតិដោយសារតែការដាក់បញ្ជីឈ្មោះបេក្ខជនព្រឹទ្ធសភារបស់ខ្លួននេះ។ ការប្រេះឆានេះនឹងធ្វើឱ្យការប៉ុនប៉ងរបស់លោក ហ៊ុន សែន ក្លាយជាអ្នកឈ្នះដោយមិនបាច់ប្រឹង ពីព្រោះគណបក្សសង្គ្រោះជាតិនឹងបែកដោយខ្លួនឯង។

បាវចនាតែមួយរបស់សង្គ្រោះជាតិដែលគេអាចជឿបានគឺៈ គណបក្សសិទ្ធិមនុស្សនឹង គណបក្សសមរង្ស៊ី"រួមគ្នានឹងឈ្នះឆ្នោត" តែបើគណបក្សទាំងពីរ"បែកគ្នានឹងចាញ់ឆ្នោត"បានទៅគណបក្សប្រជាជនដែលមិនចង់លែងដៃពីអំណាចរដ្ឋទៅហើយ -ម្ល៉ោះហើយលោក ហ៊ុន សែន ក៏ធ្វើសកម្មភាពគ្រប់បែបយ៉ាងទាំងស្របច្បាប់ទាំងរំលោភរដ្ឋធម្មនុញ្ញទាំងរំលោភសិទ្ធិរបស់មនុស្ស...ក៏អាចធ្វើបានទាំងអស់ ដើម្បីសម្រួលការបែកបាក់ផ្ទៃក្នុងសង្គ្រោះជាតិផង នឹង ហ៊ុន សែន នៅតែកាន់អំណាចដដែលផង។


កឹម សុខា


សម រង្ស៊ី


ម៉ៅ មុន្នីវណ្ណ

**គណបក្សសង្គ្រោះជាតិឈ្លោះគ្នា**ដោយសារបញ្ជីឈ្មោះបេក្ខជនព្រឹទ្ធសមាជិកៈគណបក្សសិទ្ធិមនុស្ស នឹងគណបក្ស សម រង្ស៊ី មិនដែលរលាយចូលគ្នាដោយសុទ្ធចិត្តនៅឡើយទេ ចាប់តាំងពីកំណើតនាឆ្នាំ២០១៣មក ម្ល៉ោះហើយការដម្លើងបញ្ជីបេក្ខជនព្រឹទ្ធសមាជិករបស់សង្គ្រោះជាតិក៏យោងទៅតាម"កូតាយោគយល់គ្នា"នៃគណបក្សនិមួយៗ ដោយមិនចាំបាច់គិតពីសមត្ថភាពបំរើជាតិរបស់បេក្ខជននោះទេ ។ បន្ថែមពីលើនេះនៅលើបញ្ជីឈ្មោះបេក្ខជន ក៏ត្រូវមានឈ្មោះនៃអ្នកដែលជាមនុស្សជំនិតរបស់អ្នកមានឥទ្ធិពលក្នុងគណបក្សមិនចាំបាច់មានគុណសម្បត្តិចំពោះមុខគណកម្មការនាយកនោះក៏បានដែរ ។ បញ្ជីឈ្មោះបេក្ខជងព្រឹទ្ធសមាជិកសង្គ្រោះជាតិមាន១១៦នាក់សម្រាប់អាសនៈទាំងអស់៦១គណបក្សសង្គ្រោះជាតិមានសង្ខឹមថាអាសនរបស់ខ្លួននឹកើនពី១១ នាអាណត្តិមុន ទៅជា២៥ នាអាណត្តថ្មីនេះ, បញ្ជីឈ្មោះទាងអស់បានត្រូវសម្រេចដោយគណអចិន្ត្រៃយ៏ហើយ បញ្ជូនដោយលោកប៉ុល ហំ ជាអនុប្រធានទៅកាន់លោក កឹម សុខា ជាប្រធាន ដើម្បីចុះហត្ថលេខានៅក្នុងពន្ធនាគារ តាមរយៈនិរសា គឺលោក ម៉ៅ ម៉ានីវ៉ាន ជាអនុប្រធានប្រតិបត្តិ។ បញ្ជីបេក្ខជននោះត្រូវត្រឡប់មកគណអចិន្ត្រៃយ៏វិញ មុននឹងបន្តដំណើរទៅជូនក្រសួងគជប ក៏ប៉ុន្តែមានការចោទប្រកាន់ថា លោក ម៉ៅ ម៉ានីវ៉ាន់ នៅពេលចេញពីលោក កឹម សុខា មកវិញ ក៏សំដៅទៅក្រសួងមហាផ្ទៃតែម្តង ដោយឥតឆ្លងគណអចិន្ត្រៃយ៏របស់បក្សវិញទេ ហើយបញ្ជីបេក្ខជនបានត្រូវគេនិយាយថា"បានត្រូវកែរផ្លាស់ប្តូរមិនដូចដើម"។

**លោក សម រង្ស៊ី កំពុងដើរតួ**ជាអ្នកគ្រប់

**តទៅទំព័រទី ០៧**




LICO WIRELESS & GENERAL SERVICES

**មានលក់**
-ស៊ីមកាត -ទូរស័ព្ទដៃ&ស្រោមទូរស័ព្ទដៃ-ដោះកូដបណ្តាញ GSMរបស់ទូរស័ព្ទដៃ,កុំព្យូទ័រលើតុ និងកុំព្យូទ័រយួដៃគ្រប់ប្រភេទ

**សេវាកម្ម**
-បង់ថ្លៃវិក្កយបត្រផ្សេងៗ
-ដោះកូដទូរស័ព្ទដៃគ្រប់ប្រភេទ

**ជួសជុល**
- កុំព្យូទ័រខូច/អាក្រង់ IPHONE ដែលបែក
- ធ្វើឲ្យកុំព្យូទ័រដើរលឿន (PC TUNE UP)
- កំចាត់មេរោគចេញពីកុំព្យូទ័រ
- បង្កើតអ៊ីម៉េល
- ការថតចម្លងទិន្នន័យទុក(DATA BACK UP)
- ពិនិត្យភាពមិនប្រក្រតីរបស់កុំព្យូទ័រដោយមិនគិតថ្លៃ (FREE COMPUTER DIAGNOSTIC)



សូមមកកាន់ហាងរបស់យើងខ្ញុំ ដែលមានអាស័យដ្ឋាន
336 WESTFORD STREET. LOWELL, MA
978-735-4100
បើកចាប់ពីៈ ថ្ងៃច័ន្ទ ដល់ ថ្ងៃសៅរ៍ | ពីម៉ោង១០ព្រឹក -៧យប់ / ថ្ងៃអាទិត្យ បិទ

SIBORAK ERIC PONN ស៊ីបូរ៉ាក
Coco, Early & Associates/The Dutton Group



Coco, Early & Associates
The Real Estate Professionals

564 Dutton St, Lowell MA 01854
License: MA/NH
Real Estate Agent
978-596-7935 / sponn@cocoearly.com
ស្មោះត្រង់ - សុចរិត - ការប្តេជ្ញាចិត្ត

លោក ស៊ីបូរ៉ាក់ អេរិក មានឆន្ទៈ ក្នុងការជួយសមាជិកនៅក្នុងសហគមន៍របសយើងឱ្យក្លាយជាម្ចាស់ផ្ទះ។ លោកបាននាំមកនូវបទពិសោធន៍មិនរកប្រាក់ចំណេញសម្រាប់ជួយណែនាំដល់គ្រួសារជាច្រើន ដើម្បីឲ្យសម្រេចបាននូវគោលដៅភាពជាម្ចាស់គេហដ្ឋានរបស់ពួកគេមួយជំហានម្តងៗ។ លោកមានភាពស្មោះត្រង់, គួរឲ្យទុកចិត្ត និងមានការប្តេជ្ញាចិត្ត ក្នុងការផ្តល់សេវាទិញ និងលក់ផ្ទះ ដែលគួរឲ្យកោតសរសើរ។ លោក អេរិក និយាយភាសាខ្មែរបានយ៉ាងស្ទាត់ជំនាញ។

# សម្ភាសន៍ជាមួយព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ធម្មិកោ សមាជិកជាន់ខ្ពស់គណបក្សសង្គ្រោះជាតិ

**ដោយ ពិន សំខុន ថ្ងៃទី៣វិច្ឆិកា២០១៧**

***ឡូវែល:*** *ស្ទាក់អាស្រ័យនៅរយៈពេល២ សប្តាហ៏នៅឡូវែលព្រះអង្គ ស៊ីសុវត្ថិ ធម្មិកោ បាន ផ្តល់បទសម្ភាសន៏ដល់សារពតិមានខ្មែរផុសស.រ.អា. ក្នុងពេលដែលគណបក្សសង្គ្រោះជាតិកំពុងរងនូវ ការវាយប្រហារ, ចាប់ខ្លួនប្រធាននឹងប៉ងឃាត់ខ្លួន សមាជិកខ្លះទៀត ប៉ុនប៉ងរំលាយគណបក្សពី សំណាក់រដ្ឋាភិបាលលោក ហ៊ុន សែន, ទាំងនោះ បានបង្កលក្ខណ:ស្មុគស្មាញផ្ទៃក្រៅដែលព្រះអង្គ ម្ចាស់ចេញមកស្វែងរកដំណោះស្រាយផ្លូវទូតនៅ ឯបរទេស... ស្រាប់តែបញ្ហាផ្ទៃក្នុងបក្សបានផ្ទុះ ឡើង បង្ហាញការប្រេះឆាយ៉ាងគួរឱ្យព្រួយបារម្ភ ចេញមកមួយទៀត នាពាថ្ងៃចុងក្រោយនេះ។ លោក ហ៊ុន សែន រង់ចាំតែឱកាសរបៀបនេះ ដើម្បីយកជ័យជំនះជាស្ថាពរ...តើគណបក្សសង្គ្រោះ ជាតិគេចរួចពីការរំលាយ ឬក៏ការចាញ់ឆ្នោតបាន ដែរឬទេ? សូមតាមដានបទសម្ភាសន៏ខ្មែរផុស ជាមួយព្រះអង្គម្ចាស់ធម្មិកោ ដូចតទៅ:*

**ខ្មែរផុសស.រ.អា:** ថ្វាយបង្គំព្រះអង្គម្ចាស់ ធម្មិកោ! តើព្រអង្គមានតួរនាទីអ្វីខ្លះនៅក្នុងបក្ស សង្គ្រោះជាតិ?

**ស៊ីសុវត្ថិ ធម្មិកោះ** ជំរាបសួរបង! ខ្ញុំជាសមាជិកគណកម្មកានាយកគណបក្សផង, ជាប្រធាន គណកម្មការកិច្ចការបេរទេសផង នឹងប្រធាន ក្រុមកាងារនៅខេត្តព្រះសីហនុផង។ ខ្ញុំមកនេះ ក្នុងតួនាទីមកជួបមន្ត្រីកិច្ចការបរទេសផង ក៏មក ជួបសមាជិកសមាជិកាសង្គ្រោះជាតិដែលបាន ភៀសខ្លួនមកពីកម្ពុជាមកអាមេរិក គេចពីការ គៀបសង្កត់ពិសំណាក់រដ្ឋាភិបាលផងដែរ

**ខ្មែរផុសស.រ.អា:** តើគណកម្មការនាយក ខុសគ្នាពីគណអចិន្ត្រៃយ៏យ៉ាងណា?

**ស៊ីសុវត្ថិ ធម្មិកោះ** គណកម្មការនាយក គឺ ជាអង្គការនិតិបញ្ញត្តិរបស់បក្សជាអ្នកអនុម័ទ លើគោលនយោបាយឬគម្រោងនានា រីឯគណ អចិន្ត្រៃយ៏ជាអ្នកអនុវត្តន៏នូវគម្រោង ដែលបាន ទទួលយល់ព្រមពីគណកម្មការនាយករួចហើយ ដូចគ្នានឹងរដ្ឋាភិបាលរបស់បក្សដែរ ។

**ខ្មែរផុសស.រ.អា:** ថ្មីៗនេះគណបក្សសង្គ្រោះ ជាតិបានរងនៅ"វិបត្តិផ្ទៃក្នុង"ដ៏សំខាន់មួយ គឺបញ្ជី ឈ្មោះបេក្ខជនព្រឹទ្ធសភារបស់បក្សបានត្រូវរងការ ចោទប្រកាន់ថា មាន"ជនបង្កប់"បានលួចកែបន្លំ បញ្ជីដែលបានយកទៅដាក់នៅគ.ជ.ប...រឿងនេះ បានបង្កជាវិបត្តិផ្ទៃក្នុងដ៏អស្ចារ្យមួយដែលនឹង ធ្វើឱ្យលោក ហ៊ុន សែន សប្បាយចិត្តមិនតិចទេ តើព្រះអង្គអាចពន្យល់រឿងនោះរបៀបណា?

**ស៊ីសុវត្ថិ ធម្មិកោះ** ខ្ញុំពុំទាន់ដឹងថា រឿងនោះ វាកើតរបៀបណានៅឡើយទេ នៅពេលដែល លោក សម រង្ស៊ី និយាយថាមានជនបង្កប់នោះ តើជារឿងបុគ្គល ឬក៏ជារឿងគណបក្ស? -បើ ជារឿងបុគ្គលតើវាកើតពីពេលណាមក? គឺលោក ម៉ៅ ម៉ានីវ៉ាន់ ធ្លាប់បានចាកចេញពីគណបក្សសម រង្ស៊ី បំរុងទៅចុះចូលគណបក្សប្រជាជនតែបាន ត្រូវគណបក្សសិទ្ធិមនុស្សយកបានមុន ក៏មក គណបក្សសិទ្ធមនុស្សវិញ បើគំនុំនេះកើតពីរឿង បុគ្គលយើងដោះមិនរួចទេ -រីឯរឿងគណបក្សវិញ គឺគណអចិន្ត្រៃយ៏ត្រូវពិនិត្យលើករណីយនោះ រកមើលថាតើមានកំហុសត្រង់ណា ហើយដាក់ជូន លោកប្រធាន កឹម សុខា សម្រេច លោកនៅតែជា ប្រធាននៅឡើយ ពីព្រោះលោកទទួលត្រឹមតែ ការចោទប្រកាន់នៅឡើយទេ មិនទាន់មាន កំហុសទេ។



ព្រះអង្គម្ចាស់ ធម្មិកោ កំពុងឃោសនា

**ខ្មែរផុសស.រ.អា:** លោក កឹម សុខា នៅ ពេលដែលបញ្ជាឱ្យដកយកបញ្ជីឈ្មោះបេក្ខជន មកធ្វើសារជាថ្មីវិញ តើចង់ជំរះបញ្ជី ដើម្បីបញ្ចប់ ការបែកបាក់ដែរឬទេ?

**ស៊ីសុវត្ថិ ធម្មិកោះ** រឿងនេះមាន២ដែល ត្រូវចែកឱ្យដាច់ គឺ១រឿងបញ្ជីឈ្មោះយើងបាន ធ្វើរួចហើយ គឺរៀបតាមរូបមន្តនៃកិច្ចព្រមព្រៀង សម រង្ស៊ី-កឹម សុខា ពេលបង្កើតសង្គ្រោះជាតិ នោះឡើង -ទី២គឺរឿង ម៉ៅ មុន្នីវ៉ាន់ ដែលរចនា សម្ព័ន្ធគណបក្សត្រូវពិនិត្យ ហើយអនុវត្តន៏តាម ច្បាប់គណបក្សដែលយើងត្រូវរង់ចាំជំហ៊ារលោក ប្រធាន កឹម សុខា ...

**ខ្មែរផុសស.រ.អា.** នៅពេលដកបញ្ជីមក មើល តើមានឃើញថា អ្នកណាជាប្តូរបញ្ជីដែរ ឬទេ?

**ស៊ីសុវត្ថិ ធម្មិកោះ** អត់មានទេ! គេឈ្វូស បញ្ជីឈ្មោះចាស់នោះតែម្តង ហើយដាក់ឈ្មោះ ថ្មីទៅតាមរូបមន្តដែលបានព្រមព្រាងគ្នារួចហើយ

**ខ្មែរផុសស.រ.អា:** ដូច្នេះ តើអាចមានកំហុស របស់គណអចិន្ត្រៃយ៏ ដែលដាក់បញ្ជីឈ្មោះឱ្យគេ យកទៅគ.ជ.ប. បែរជាមានកំហុសអ្នកនាំសារ ទៅវិញ អានេះគេហៅថា "ស្វាបានបាយស៊ីយក ទៅលាបមាត់ពពែ"មែនទេ?

**ស៊ីសុវត្ថិ ធម្មិកោះ** នេះគេអាចថា មានមនុស្ស មានកំហុសច្រើនគ្នា គេឈ្វូសចោលតែម្តងទៅ កុំឱ្យខាតពេលច្រើន...

**ខ្មែរផុសស.រ.អា:** ខ្ញុំបានឃើញសេចក្តីថ្លែង ការខ្វែងគ្នា ដូចជាលោករង្ស៊ីថា "លោក សុខា នៅ ក្នុងគុក កុំសូវទុកចិត្តខ្លាំងពេកខ្លាចមានពាក្យក្លែង ក្លាយ" ឯលោក សុខា វិញថា កុំឱ្យលោក រង្ស៊ី និយាយពាក្យអ្វីដែលបំបែកបំបាក់ផ្ទៃក្នុង ជា សញ្ញាថា"អ្នកទាំងពីរបានបែកគ្នាហើយ" មែន ទេ?

**ស៊ីសុវត្ថិ ធម្មិកោះ** បើជាគោលការ ឬទិស

**តទៅទំព័រទី ០៥**



## តមកពីទំព័រទី ០៤ សម្ភាសន៍ជាមួយព្រះអង្គម្ចាស់ ធម្មិកោ...

ដៅអ្នកទាំងពីឥតមានបែកគ្នាទេ -ហើយបើជាប្រយោជន៍ ក៏ឥតបែកគ្នាដែរ ពីព្រោះតែខុសគ្នាទាំងអស់គ្នានឹងស្លាប់ហើយ, នៅសល់តែយុទ្ធសាស្ត្រ ដែលខ្ញុំមានឧទាហរណ៍ថា លោក សុខា ចង់បានដំណោះស្រាយ"ឱ្យគេដោះលែងលោក ដើម្បីឱ្យបានទៅបោះឆ្នោតមួយដែលត្រឹមត្រូវ" ចំណែកលោក រង្សី ចង់បានដំណោះស្រាយជា"កញ្ចប់មួយដែលមានការដោះលែងលោក សុខា ផង បោះឆ្នោតត្រឹមត្រូវផង នឹងរូបលោកក៏អាចត្រឡប់ទៅស្រុកខ្មែរធ្វើនយោបាយវិញដែរ...ហ្នឹងហើយដែលខុសគ្នាសម្រាប់ដំនោះស្រាយកម្ពុជានោះ...

**ខ្មែរផុសស.រ.អា:** ក្នុងឧទាហរណ៍នេះ ខ្ញុំក៏ឃើញថាមានអយុត្តិធម៌ចំពោះ សម រង្សី ដែរ ដែលគាត់លាលែងដោយសារតែគណបក្សតស៊ូក៏ដើម្បីគណបក្សគួរតែទាមទារជាកញ្ចប់រាប់ទាំងរូបគាត់ផង ទើបសម តើព្រះអង្គគំនិតដូចទូលបង្គំទេ?

**ស៊ីសុវត្ថិ ធម្មិកោ:** ខ្ញុំមិនអាចជូនយោបល់ពីរឿងនេះបានទេ លើទស្សនៈបុគ្គលរបស់មនុស្សដែលជាប្រធានរបស់ខ្ញុំ ខ្ញុំសូមលើកពីករណីអូនសាំន់ស៊ូជីនៃប្រទេសភូមាគាត់ជាប់គុកច្រើនឆ្នាំណាស់ ដល់គណបក្សគាត់ជាប់ឆ្នោត ទើបបានគាត់បានរួចពីកគុកអន្តរជាតិគេឥតជួយបុគ្គលទេ តែគេជួយឱ្យមានការបោះឆ្នោតត្រឹមត្រូវ...នៅមានឧទាហរណ៍មួយទៀត ដូចជាលោក ណេលសុន ម៉ង់ដែឡា នៃអហ្វ្រិកខាងឈ្នះត្បូងជាប់គុកច្រើនឆ្នាំ គេជួយឱ្យមានការបោះឆ្នោតមនតែឥតបានជួយជាបុគ្គលទេ ទាល់តែគណបក្សឈ្នះ ទើបបានគាត់ចេញមក...ខ្ញុំសុំទោសលោកប្រធានទាំងពីរ ចំពោះទស្សនៈរបស់ខ្ញុំនេះ ខ្ញុំមិនជឿថា "គេនឹងមកជួយជាបុគ្គលទេ គេអាចនឹងមកជួយយើងឱ្យមានការបោះឆ្នោតមួយដោយសេរីនឹងយុត្តិធម៌បាន"...តែខ្ញុំនៅតែជម្រុញឱ្យមានដំណោះស្រាយជាកញ្ចប់តែដដែលទេ...

**ខ្មែរផុសស.រ.អា:** ឥឡូវយើងងាកមកមើលពីខាងគណបក្សប្រជាជនវិញម្តងគេបណ្តេញលោក រង្សី ឱ្យចេញមកនៅក្រៅប្រទេសចាប់លោកសុខាដាក់ពន្ធនាគារ...។ល។ ថា "តើគណបក្សនេះនឹងធ្វើអ្វី ដើម្បីឱ្យនៅតែកាន់អំណាចដដែល?

**ស៊ីសុវត្ថិ ធម្មិកោ:** សម រង្សី - កឹម សុខា រួមគ្នាមានកម្លាំងខ្លាំងខ្លាណាស់ ដូច្នេះត្រូវបំបែកឱ្យចេញពីគ្នា គឺរុញលោក សម រង្សី ឱ្យចេញមកក្រៅ ដើម្បីស្រួលគេខ្សិបម្ខាងម្តង... ចំណែកឯ កឹម សុខា ជាប់គុកជារឿងមួយទៀត, លោករាជរដ្ឋាភិបាលបានអញ្ជើញអ្នកឯកទេសអ៊ីស្រាអែលឱ្យមកធ្វើការស្ទង់មតិមួយជុំវិញការបោះឆ្នោតឃុំសង្កាត់ផង នឹងបោះឆ្នោតជាតិផង សម្រាប់ឆ្នាំ ២០១៧-១៨- លទ្ធផលទទួលបានគឺ ១-គណបក្សប្រជាជនទល់នឹងសង្គ្រោះជាតិដែលមាន សម រង្សី លទ្ធផល គឺបាន៣២ ទល់នឹងរង្សី ៤៦% ២-គណបក្សប្រជាជនទល់នឹងសង្គ្រោះជាតិដែលមានតែ កឹម សុខា តែម្នាក់ឯងនឹងបាន ៣៣% ទល់នឹង សុខា ៤២% ៣-គណបក្សប្រជាជនទល់នឹងសង្គ្រោះជាតិដែលឥត សម រង្សី - ឥត កឹម សុខា នឹងបាន៣២% ទល់នឹងសង្គ្រោះជាតិ ៣៣% ដូច្នេះករណីដែលលោក ហ៊ុន សែន អាចធ្វើការយកជ័យជំនះបានលុះត្រាតែគ្មាន សម រង្សី ផង នឹងគ្មាន កឹម សុខា



ថែមទៀត - ហើយបើបោះឆ្នោតមានអ្នកទាំង២នាក់ចូលប្រឡូកនឹងនយោបាយ គឺលោក ហ៊ុន សែន នឹងធ្វើអត្តឃាត ដូច្នេះលោកនឹងធ្វើយ៉ាងណាមិនឱ្យការបោះឆ្នោតដោយមាន"សម រង្សី នឹង កឹម-សុខា"ចូលរួមបានឡើយ...ជម្រើសមានតែមួយហ្នឹងទេដែលជារូបភាពនយោបាយលោក ហ៊ុន សែន ទៅថ្ងៃមុខ គឺមិនរំលាយគណបក្សសង្គ្រោះជាតិទេ តែទុក សម រង្សី នៅក្រៅ នឹងទុក កឹម សុខា ក្នុងគុក...

**ខ្មែរផុសស.រ.អា:** ចុះបើសិនបើសិនជាត្រូវ

**តទៅទំព័រទី ២០**




| ទំហំគ្រួសារ | ប្រាក់ចំណូល |
|---|---|
| 1 | $34,380 |
| 2 | $44,958 |
| 3 | $55,537 |
| 4 | $66,115 |
| 5 | $76,693 |
| 6 | $87,272 |

# បោះឆ្នោត: ចំណាយ១០០លានបន្ថែមសម្រាប់"ដោនថោន៣"

ដោយ អាដាម ព្រិល

"ព័ត៌មានថ្មីមួយទើបនឹងផ្សាយដោយវិទ្យុ WCAP នឹងកាសែតឡូសាន់ នាព្រឹកនាព្រឹកទី៣ វិច្ឆិកា នេះថា: លោកមេធាវី ភីទ័រ ហ្លីន Peter Flint បានទទួលភាពជាតំណាងឱ្យការិយាល័យវេជ្ជបណ្ឌិត ៦នាក់ នឹងម្ចាស់នៃអាគារមួយចំនួនដែលឋិតនៅលើគម្រោង"ដោនថោនគម្រោងទី៣"ឱ្យត្រៀមដាក់ពាក្យបណ្តឹងក្រុងឡូវែល ពីករណីយដែលនឹងមានសេចក្តីសម្រេចធ្វើសំណង់វិទ្យាល័យ "ឡូវែល"ឱ្យត្រឡប់មកនៅ"ដោនថោន"វិញ ពេលនោះគេនឹងប្តឹងទារសំណងថ្លៃអាគាររបស់ពួកគេបន្ថែមពីលើថវិការដែលបានផ្សព្វផ្សាយហើយចំនួន៣៨០លានដុល្លានោះ ប្រមាណជា៤០លាននេះមិនទាន់គិតពិការខាតបង់ប្រាក់ចំណូលនៅពេលដែលទៅកន្លែងថ្មីដែលត្រូវរង់ចាំ២ឆ្នាំទម្រាំដំណើរការបាន។

ម្យ៉ាងវិញទៀតលោក ហ្លីន បានឱ្យដឹងថាម្ចាស់លុយ MSBA មិនចូលចិត្តចំណាយលុយច្រើនទៅលើសំណង់ចាស់ដែលមានអាយុ២០០ឆ្នាំទៅហើយនោះទេ ពីព្រោះជាទូទៅនៅលើអាគារចាស់របៀបនេះ វានឹងមានការជួសជុលឥតប្រៀងទុកដែលគេមើលមិនឃើញប្រមាណពី ៨-១២% នៃគម្រោងដើមថែមទៀត។ ដូច្នេះឡូវែលត្រូវត្រៀមខ្លួន ចេញលុយបន្ថែមប្រហែលជា១០០លានទៀតទើបគ្រប់។ ផ្ទុយគ្នានឹង"ខលី" គេអាចគ្រោងថវិការបានច្បាស់លាស់ជាង ហើយបានសាលារៀនថ្មីស្រឡាងថែមទៀត៕


សាលាក្រុងឡូវែល

KhmerPost USA

## ថ្ងៃ៧ វិច្ឆិកា ២០១៧
## បោះឆ្នោតសម្រាប់ឈ្នះនៅឡូវែល

១-បោះឆ្នោត "No"ឆ្លើយនឹងសំនួរទី១ - ខ្មែរផុសស.រ.អា គាំទ្រសាលារៀននៅ"ខលី"

- ធ្វើបានសាលារៀនថ្មីហើយ សាលាចាស់អាចលក់ ឬជួលបាន (ទប់ស្កាត់ពាក់កុំឱ្យឡើងថ្លៃបាន)
- ចម្ងាយពីក្រុងខ្មែរទៅសាលារៀនថ្មី ស្មើរគ្នា - មាន "ស្គូលប៊ីស"ច្រើន (មិនគួរឱ្យសិស្សដើរកាត់ភ្លៀង ឬកាត់ព្រិលទេ)
- រក្សាប្រវត្តិសាស្រ្តក្រុងបាន ពីព្រោះអាគិតនៅទីនោះដដែល(សូមមើលអាគិ Wang ឥឡូវទៅជា MCC មានបាត់ទៅណា?)
- អ្នកប្រកាន់"ដោនថោន"បានចាញ់ការបោះឆ្នោត២ដងហើយ: ដូច្នេះ"ខលី"ជាសម្លេងត្រឹមត្រូវនឹងមានអនាគតជាង

២-បោះឆ្នោតឱ្យបេក្ខជនខ្មែរ នឹងបេក្ខជនសាសន៏ផ្សេង ដែលឧស្សាហ៏មកសង្គមខ្មែរដោយមិនចាំបាច់អញ្ជើញ

- ខ្មែរមាន"បេក្ខជនខ្មែរ៣រូប"ដែលមានសមត្ថភាព គឺវាំស្នា នួន, សុខារី ចៅ នឹង ដូមីនីក ឡាយ - រួមទាំង "បេក្ខជនសាសន៏ផ្សេង" ដែលស្រឡាញ់វប្បធម៌ខ្មែរ គឺជាកម្លាំងនៃអនាគតខ្មែរ ។

**-បេក្ខជនសាលាក្រុងមាន:** Veasna Noun - Sokhary Chau - Rodney Elliott - Rita Mercier - Corey Ballenger Dan Rourke - Robert Gignac -John Leahy - William Samaras ។

**-បេក្ខជនគណកម្មការសាលារៀន :** Dominik Lay - Connie A Martin - Timothy Blake - Noelle M. Creegan - Dennis R Mercier - Gerard G Nutter

- យើងអាចប្រស្រ័យទាក់ទងដោយមិនចាំបាច់ខ្លាចចិតនឹងដោយកិតិយស ពីព្រោះគេកាន់តែស្គាល់យើងច្បាស់ឡើង

៣-សូមគូសយ៉ាងហោចណាស់ឱ្យបាន៥រូបសម្រាប់បេក្ខជន"សាលាក្រុង"នឹង៤រូបសម្រាប់គ.ក"សាលារៀន"

- ចំនួនសម្លេង"ពាក់កណាល +១" គឺជាជោគជ័យនៃ"គំនិតនឹងបំណង"ម្ចាស់ឆ្នោតនៅ"សាលាក្រុងនឹងនៅ "សាលារៀន"
- លោកអ្នកជាអ្នកមានគុណលើបេក្ខជនដែលលោកអ្នកបានបោះឆ្នោតឱ្យ ដូច្នេះងាយស្រួលនឹងទៅរកគេ ពេលត្រូវការ ។

៤-អ្នកជំនួញច្រើនថា "រវល់ពេក"ទៅបោះឆ្នោតមិនបាន: ត្រូវនឹកថា ឆ្នោត"ឈ្នះ"សម្រាប់អ្នករកស៊ីនោះហើយ

- ពាក់បានឡើងថ្លៃច្រើន ដូច្នេះអ្នកជំនួញត្រូវ"ចាប់តំណាងក្រុងរបស់ខ្លួន" ទប់កុំឱ្យពាក់ត្រូវតំឡើងស្រេចនឹងចិតបាន
- ត្រូវបញ្ជូនអ្នកធ្វើការក្នុងហាងឱ្យទៅបោះឆ្នោតកុំខាន អ្នកធ្វើការក្នុងហាង គឺជាសម្លេងរបស់ហាងជំនួញលោកអ្នក

៥-អ្នកទាំងអស់គ្នា អាចទៅបោះឆ្នោតមុនក៏បាន ថ្ងៃទី៧ វិច្ឆិកានោះ មានពេលពេលមួយថ្ងៃ

- សម្រាប់អ្នករវល់ខ្លាំង ទៅបោះឆ្នោតមុនពេលក៏បានដែរ បង្កើនចំនួនអ្នកបោះឆ្នោតខ្មែរក្នុងឡូវែល គឺជា "កម្លាំង" ធ្វើឱ្យគេខ្លាចសម្លេងចំនួនអ្នកបោះឆ្នោតច្រើន៕


# រីតា មើស៊ីយៀ

## នៅថ្ងៃទី០៧ វិច្ឆិកា ឆ្នាំ២០១៧

លោកអ្នកមានឱកាសនឹងបញ្ចេញមតិ
នៅលើសិទ្ធជាមូលដ្ឋានដ៏សំខាន់មួយ
គឺ"សិទ្ធិបោះឆ្នោត"

សូមអញ្ជើញបោះឆ្នោតឱ្យខ្ញុំ ជាថ្មីម្តងទៀត
បោះឆ្នោតឱ្យលេខ ៦
**Rita M. Mercier**
លេខ៦ នៅលើសន្លឹកឆ្នោត ។
សូមអរគុណ!

**On Tuesday, November 7th
You have the opportunity to express one of your most basic rights,
"The right to vote"
Please,
Vote for me once more
Vote for #6**



**Rita M. Mercier
#6 on the ballot.
Thank you.**

តមកទំព័រទី ១៤

## គណបក្សសង្គ្រោះជាតិចង់រំលាយ...

គ្រងក្នុងគណបក្សសង្គ្រោះជាតិនៅឡើយៈ ដោយមានការបង្ហោះសារដោយចំពោះ ឬមិនចំពោះជូនប្រជាជាតិរបស់លោកអតីតប្រធាន សម រង្ស៊ី ជាពិសេសផ្ញើរជូនទៅសមាជិកសមាជិការបស់គណបក្សនៅពេលដែលគណកម្មការនាយកពុំទាន់មានសេចក្តីសម្រេចច្បាស់លាស់ក្នុងរឿងណាមួយនឹងនៅពេលដែលប្រធាននៃគណបក្សកំពុងជាប់នៅក្នុងពន្ធនាគារ។ បន្ថែមពីនេះមានទាំងចេញបញ្ជារពីលោក សម រង្ស៊ី កុំឱ្យគេឯងជឿសាររបស់ប្រធានគណបក្សដែលកំពុងជាប់ពន្ធនាគារ ព្រមទាំងផ្សព្វផ្សាយបញ្ចេញការចោទប្រកាន់ថាមានសមាជិកជាន់ខ្ពស់ណាមួយក្បត់បក្ស(ដោយចង្អុលចំឈ្មោះ ម៉ៅ ម៉ានីវ៉ាន់) ជំនួសតួនាទីរបស់គណកម្មការនាយកទៀតផងនោះ ធ្វើឱ្យគេយល់ថា លោក សម រង្ស៊ី នៅមានឥទ្ធិពលលាក់កំបាំងណាមួយក្នុងបក្សនៅឡើយ ។

គណកម្មការនាយកពុំមានគោលដៅច្បាស់លាស់សម្រាប់គ្រប់គ្រងវិបត្តិរួមគ្នាៈ សមាជិកគណអចិន្ត្រៃយ៍មួយចំនួន(ភាគច្រើន)កំពុងភៀសខ្លួននៅក្រៅប្រទេស (ហើយនៅទីកន្លែងឆ្ងាយពីគ្នា)មួយចំនួនតូចនៅក្នុងប្រទេសជាដើមហេតុនៃការមិនបានជួបគ្នាសម្រេចវិបត្តធំៗរបស់បក្សម្លោះហើយសេចក្តីប្រកាសនានារបស់លោក សម រង្ស៊ី គឺជាចំណីនៃការយល់មិនច្បាស់លាស់ ឬក៏យល់ច្រឡំពីបំណងរបស់គណកម្មការអចិន្ត្រៃយ៍



លោក ប៉ុល ហំ
អនុប្រធានគណបក្សសង្គ្រោះជាតិ

សង្គ្រោះជាតិ នៅក្នុងព្រឹត្តិការតឹងតែងណាមួយ។ មួយទៀត លោក កឹម សុខា ជាប្រធានគណបក្សសង្គ្រោះជាតិបានត្រូវលោក ហ៊ុន សែន ដាក់ពន្ធនាគារពីព្រោះតែជាប្រធានគណបក្សដែលអាចនឹងដឹកនាំការឈ្នះឆ្នោតយកអំណាចពីដៃគណបក្សប្រជាជនបាននោះ ក៏មិនមានលទ្ធភាពជួបដោយសម្ងាត់ជាមួយសមាជិកគណបក្សណាម្នាក់ថែមទៀតនោះ មិនអាចពន្យល់ពីបំណងរបស់ខ្លួន ឬរបស់បក្សបានឡើយ។ លោក កឹម សុខា បាន"ចេញបញ្ជាឱ្យដកយកបញ្ជីបេក្ខជន"នោះមកវិញ ដើម្បីកែរតម្រូវ ហើយធ្វើឱ្យតាមនិតិវិធីដែលមានចែងក្នុងលក្ខន្តិកៈរបស់បក្សនេះដើម្បី "ទប់ស្កាត់ការប្រេះឆាផ្ទៃក្នុង"ថែមទាំងបញ្ចេញសារទៅកាន់លោក សម រង្ស៊ី ឱ្យបញ្ឈប់បញ្ចេញសារដែលនាំឱ្យបែកបាក់ផ្ទៃក្នុងនោះជាបន្តរទៅទៀត្ស តែដំណឹងពិការប្រេះឆានេះបានផ្សព្វផ្សាយតាម"ហ្វេសប៊ុក"រួចទៅហើយ។ វចនាសម្ព័ន្ធជាក្បាលម៉ាស៊ីនរបស់គណបក្សសង្គ្រោះជាតិប្រែជាបែកបាក់គ្នាគួរឱ្យបារម្ភភាពទន់ជ្រាយនេះ ក៏ដោយសារតែរដ្ឋាភិបាលលោក ហ៊ុន សែន "វាយប្រហារប៉ុនប៉ងរំលាយគណបក្ស"មួយនេះដោយចំហរ តាំងពីច្រើនខែមកហើយ ចុងក្រោយបង្អស់ការប្រកាសរកចាប់ខ្លួនមន្ត្រីសង្គ្រោះជាតិដែលបាននិយាយប៉ះពាល់តិចឬច្រើនដល់រូបលោក ហ៊ុន សែន ក៏បណ្តាលឱ្យមានការរត់ភៀសពីការចាប់ខ្លួនចេញក្រៅប្រទេសក៏ច្រើនគ្នាហើយដែរ ។

គណអចិន្ត្រៃយ៍ពេលនេះ ជាជំហ៊ានជំនួសឱ្យគណបក្សទាំងមូលដែលមិនមូលគ្នាធ្វើសេចក្តីសម្រេចក្នុងបក្សបន្ថែមពីនេះ ការខ្វះប្រធានហើយមិនបានជំនួសដោយតួរនាទី"ស្តីទី"ក៏ជាកង្វះដ៏សំខាន់មួយក្នុងវចនាសម្ព័ន្ធបក្សសង្គ្រោះជាតិផង ដែលជាហេតុនៃការងាយស្រួលនឹងបែកបាក់គ្នា។

ដោយសារមានតំនាបពីសហគមន៍អន្តរជាតិចំពោះការរំលោភសិទ្ធិមនុស្សរំលោភរដ្ឋធម្មនុញ្ញរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន គេសង្ឃឹមថាៈ លោក កឹម សុខា នឹងត្រូវដោះលែង តែនៅសវនាការជាមួយតុលាការកំពូល កាលពីថ្ងៃទី៣០តុលានេះ បង្ហាញផ្ទុយទៅវិញ, លោក កឹម សុខា បានត្រូវដាក់បន្តរឱ្យនៅក្នុងមន្ទីឃុំឃាំងមិនបានចេញរួចមកទេ។ គេអាចយល់បានថា "ការដោះលែងលោក កឹម សុខា នាពេលនេះ គឺនឹងផ្តល់ភាពអាម៉ាស់ដល់លោក ហ៊ុន សែន, តែគេរឹតតែមិនយល់ថែមទៀតនោះថា ហេតុអ្វីក៏លោក សម រង្ស៊ី ព្យាយាមរើកកាយលាងខោអាវក្រខ្វក់នៅមុខសាធារណជន តើដើម្បីអ្វី? នៅពេលដែលសហគមន៍អន្តរជាតិ គេកំពុងរកមធ្យោបាយជួយកម្ពុជាទៅហើយនោះ។ គេកំពុងរង់ចាំការវិវត្តន៍នយោបាយនឹងទៅជាយ៉ាងណា នាអនាគតយ៉ងខ្លីខាងមុខនេះ៕


អ្នកអាចមានលក្ខណៈគ្រប់គ្រាន់ចំពោះ
ការធានារ៉ាប់រងសុខភាពដែលមានតម្លៃទាប រឺមិនគិតថ្លៃ
កុំនៅរងចាំ, មកទទួលធានារ៉ាប់រងឥឡូវនេះ

កម្មវិធី
ចុះឈ្មោះ
ធានារ៉ាប់រងសុខភាព
ថ្ងៃព្រហស្បតិ៍ ទី៩ ខែវិច្ឆិកា
ម៉ោង ៣:០០ រសៀល ដល់ម៉ោង ៧:០០ យប់

តើលោកអ្នកមានសំនួរអំពីការធានារ៉ាប់រងនៅឯសាលារបស់លោកអ្នកដែររឺទេ? តំណាងរបស់យើងខ្ញុំមានពេលដើម្បីឆ្លើយតមរាល់សំនួររបស់លោកអ្នក

មានជំនួយភាសា អង្លេស, អេសប៉្សាញ, ប័រទុយហ្គាល់, និងខ្មែរ

ពេលវេលា
ថ្ងៃព្រហស្បតិ៍
ទី៩ ខែវិច្ឆិកា ឆ្នាំ ២០១៧
ម៉ោង ៣:០០ រសៀល ដល់ម៉ោង ៧:០០ យប់

ទីកន្លែង
UMass Lowell, Univrsity Crossing, Lobby Area
ផ្លូវ 220 Pawtucket Street
Lowell, MA 01854
កន្លែងចតរថយន្តនៅ Fletcher Street Lot
ដែលមានទីតាំងនៅ University Crossing



អ្វីដែលអ្នកត្រូវនាំមកជាមួយមាន
រូបថត ID នៃមេគ្រួសារ (ឧ. ប័ណ្ណបើកបរ រឺលិខិតឆ្លងដែន)
លេខកូដសម្គាល់ខ្លួន(Social Security) គ្រប់សមាជិកទាំងអស់ក្នុងគ្រួសារ
ឯកសារអន្តោប្រវេសន៍ (សម្រាប់អ្នកមិនមែនជាសញ្ជាតិអាមេរិក)
ឯកសារធ្វើពន្ធពីឆ្នាំមុន (ប្រសិនបើមាន)
ភស្តុតាងបញ្ជាក់ពីចំណូល (សែកប្រាក់ឈ្នួលថ្មីៗបំផុតចំនួន ២)
កាតធានារ៉ាប់រង រួមមានធានារ៉ាងរងនៅសាលា (ប្រសិនបើមាន)

សម្រាប់ព័ត៌មានបន្ថែមៈ ទំនាក់ទំនង Deolina Daveiga ជាអ្នកសម្របសម្រួលសហគមន៍, Health Care For All / ទូរសព្ទ័លេខ (៦១៧)-២៧៥-២៩៣៨
ដោយសារសុខភាពរបស់លោកអ្នក, វាជាសិទ្ធរបស់អ្នក

University Health Plans, Inc. A RISK STRATEGIES COMPANY
HEALTH CONNECTOR
HEALTH CARE FOR ALL
UMASS LOWELL
CMAA

## តមកទំព័រទី ០១ ដំណើររបស់ប្រធានាធិបតី ត្រម...

ក៏មានជំហ៊ានឹងគុណភាពរឹងមាំដូចគ្នាអាមេរិកបានដាក់មូលដ្ឋានយោធាដ៏សំខាន់សម្រាប់ភាគខាងជើងនៃមហាសមុទ្រប៉ាស៊ីហ្វិកសម្រាប់ទប់ទល់នឹងប្លុកកុម្មុយនិស្ត ដែលបច្ចុប្បន្នមាន រុស្ស៊ី-ចិន-កូរ៉េខាងជើងនឹងវៀតណាម ។

២-ប្រទេសវៀតណាមមានទំនាស់នឹងចិនដោយបញ្ហានយោបាយ"ពង្រីកឥទ្ធិពលនឹងទឹកដី" គេអាចមើលឃើញបំណងវៀតណាមចង់ងាកចេញពីសម្ព័ន្ធកុម្មុយនិស្តជាមួយនឹងចិនដែលជាប្រទេសដ៏គ្រោះថ្នាក់ណៅជាប់ព្រំប្រទល់គ្នា ។ "ដាណាង"គឺជាកំពុងផែវៀតណាមជួលឱ្យអាមេរិកាំងសាជាថ្មី ដែលជាលោកប្រធានាធិបតី ត្រម ដាក់ជាដំណាក់ការចុះចតមួយ ដើម្បីជួបកងទ័ពអាមេរិកាំងដែលកាពារតំបន់សមុទ្រប៉ាស៊ីហ្វិកផ្នែកខាងត្បូង, គេអាចយល់បានថាគឺជាតំបន់ថ្មីដែលត្រូវពង្រឹងចាប់តាំងពីអាមេរិកាំងដកទ័ពថយពីវៀតណាមទុកផ្លូវឱ្យប្រទេសចិនមានវិសាលភាពគ្រប់គ្រងមហាសមុទ្រប៉ាស៊ីហ្វិកខាងត្បូង"យ៉ាងមានសេរី" ដែលបណ្តាលឱ្យប្រទេសអាស៊ីនៃតំបន់ប៉ាស៊ីហ្វិកប្រឈមនឹងការគំរាមកំហែងយ៉ាងគួរឱ្យព្រួយបារម្ភ។


ប្រធានាធិបតីថ្មីកូរ៉េខាងត្បូង និង ដណល ត្រម


ប្រធានាធិបតីស៊ី ជួបជាមួយ ដណល ត្រម


ប្រធានាធិបតីជប៉ុន ជួបជាមួយ ដណល ត្រម

៣-ហាណូយទីក្រុងនៃប្រទេសវៀតណាមជាទីដែលអាចនឹងមានការផ្លាស់ប្តូរ"កម្លាំងឥទ្ធិពលនយោបាយ"នៅក្នុងតំបន់ដែលប្រធានាធិបតីឌណល ត្រមទៅចូលរួមប្រជុំនៅទីនោះ។ បញ្ហាវិបត្តិកម្ពុជាក៏អាចនឹងដោះស្រាយនៅទីនោះដែរបើលោកនាយករដ្ឋមន្ត្រីខ្មែរ ហ៊ុន សែន នៅតែប្រើឥទ្ធិពលរបស់ចិន ហើយវៀតណាមជាអ្នកដឹកនាំឱ្យឈ្នះសង្គ្រាមលើក្រុម ប៉ុល ពត នៅកម្ពុជាហើយមិនចង់ឃើញថា ចិនកំពុងតែឈ្នះទឹកចិត្តខ្មែរ នាពេលនេះ -លោកប្រធានាធិបតី ឌណល ត្រម ថ្វីត្បិតតែមិននិយាយអ្វីពីកម្ពុជា តែលោកបានគម្រាមនៅជប៉ុនទៅដល់ជនផ្តាច់ការថា "ឱ្យត្រៀមខ្លួនឱ្យហើយទៅ!"- រីឯក្រុមការងាររបស់លោកនៅឯអាមេរិកកំពុងតែរៀបគម្រោងសម្រាប់បញ្ឈរលទ្ធិប្រជាធិបតេយ្យនៅកម្ពុជាឡើងវិញយ៉ាងសកម្មហើយ ។

៤-ប្រទេសចិន កំពុងតែប្រើឥទ្ធិពលកម្លាំងសេដ្ឋកិច្ចរបស់ខ្លួន ដើម្បីពង្រឹងកម្លាំងកងទ័ពហើយវាតតឥទ្ធីពលខ្លួននៅតំបន់ប៉ាស៊ីហ្វិកទាំងមូលដោយមានបំណងរួមកម្លាំងជាមួយនឹងរុស្ស៊ី- បានប្រើកម្លាំងយកប្រជុំកោះ"ប៉ារ៉ាសែល"នៅប៉ាស៊ីហ្វិករបស់ប្រទេសតូចៗដោយមិនឱ្យនរណាហ៊ានតវ៉ាឡើយ ប្រើលុយដុល្លារាប់រយលានសម្រាប់ទិញប្រធានាធិបតីហ្វីលីពីន ទិញនាយករដ្ឋមន្ត្រីខ្មែរឱ្យបែរមកយកសម្ព័ន្ធភាពជាមួយខ្លួនដោយផ្ទួរនឹងការកាន់ក្តាប់អំណាចរបស់គ្រួសារនៃមេដឹកនាំប្រទេសទាំង២នោះ។ បញ្ហាដែលអាមេរិកាំងនឹងទៅនិយាយជាមួយនឹងចិនការវាយប្រហារនឹងរំលាយ"អាវុធនូក្លេអ៊ែរ"នៅកូរ៉េខាងជើងដែលកំពុងមានការឃើតយ៉ាវនឹងចាប់ផ្តើម ពីព្រោះកូរ៉េខាងជើងដែលហ៊ានក្អេងក្អាង ក៏ដោយសារតែអាងលើកម្លាំងសម្ព័ន្ធភាពជាមួយនេប្រទេសចិន។

៥-ប្រទេសហ្វីលីពីនជាដំណាក់ការចុងក្រោយបង្អស់របស់លោកប្រធានាធិបតីត្រម គឺជាការជួបមុខជាមួយអតីតនៃប្រមុខសម្ព័ន្ធមិត្តដ៏មានអំណាចជាមួយប្រធានាធិបតីហ្វីលីពីន "ឌូទែទី"ដែលកំពុងតែក្បត់អាមេរិកទៅចូលនឹងចិន។ ហ្វីលីពីនធ្លាប់ជាសម្ព័ន្ធមិត្តអាមេរិកាំងដ៏រឹងមាំមួយនៅប៉ាស៊ីហ្វិក តែស្រាប់តែបែរក្បាលទៅរកចិនយ៉ាងទាន់ហន់ថែមទាំងជេអាមេរិកយ៉ាងចាស់ដៃ... យើងមិនហ៊ានទាយថា អាមេរិកនឹងទៅស្វែងរកអ្វី? ឬរបៀបណា? នៅឡើយទេ រឿងបែរក្បាលរបស់ប្រធានាធិបតី"ឌូទែទី"បានកើតស្របគ្នានឹងការបែរក្បាលពីវៀតណាមរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ទៅរកចិននៅពេលជាមួយគ្នា...សង្ឃឹមថា ដំណើរទៅហ្វីលីពីនរបស់លោកប្រធានធិបតីត្រមមិនមែនជាការផ្សងពេង្រនោះទេ សម្រាប់ហ្វីលីព្ពីននោះឡើយ។

លោកប្រធានាធិបតីត្រមជាប្រធានាធិបតីដែលគេពិបាកនឹងទាយទុកមុន ថានឹងទៅអាស៊ីទៅធ្វើអ្វី? ដោយសារចំណេះនឹងទន្លាប់របស់លោកមិនដូចប្រធានាធិបតីឯទៀតៗធ្លាប់ធ្វើពីមុនមកទេ, តាំងតែពីលោកមកកាន់អំណាចនៅសេដ្ឋវិមាន ១ឆ្នាំមកហើយ មានរឿងប្លែកៗជាច្រើនបានកើតខុសទម្លាប់រួចមកហើយ។ សូមរង់ចាំស្តាប់ការរៀបរាប់របស់ខ្មែរផុសស.រ.អា. យើងនឹងរៀបរាប់ជាបន្តរបន្ទាប់ ពីសកម្មភាពប្រធានាធិបតីត្រម ជូនជាសណ្តាប់នៅលេកក្រោយៗទៀត៕


ខ្ញុំនៅជាមួយពលរដ្ឋខ្មែរជានិច្ចនៅពេលត្រូវការខ្ញុំ




ខ្ញុំបានដឹកនាំការប្រឹងប្រែង ដើម្បីជាកិត្តិយសដល់ពលរដ្ឋខ្មែរ ដោយកសាងរូបសំណាកខ្មែរភាសខ្លួន នៅសាលាក្រុងឡូវែល សូមឲ្យទាំងនេះ ជាសញ្ញានៃការស្រលាញ់ និងគោរព របស់យើង ចំពោះពលរដ្ឋខ្មែរទាំងអស់



សូមបោះឆ្នោតឲ្យ
លោក រ៉តនី អ៊ីលីយ៉ុត
នៅថ្ងៃទី ០៧ លេខ២
នៅលើប័ណ្ណបោះឆ្នោត




RODNEY
ELLIOTT
CITY COUNCIL

Paid for by the Committee to Election Rodney Elliott.

# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

## AccuCare
### Home Care Agency
Group Adults Foster Care Program

កម្មវិធី Group Adult Foster Care (GAFC) គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើងដែលមានបញ្ហារាំរ៉ៃផ្នែកសុខភាព ឬជរាហើយមិនចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើង តាមរយៈការផ្តល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។





ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :

- រស់នៅផ្ទះរដ្ឋ
- អាយុ ២២ ឆ្នាំឡើងទៅ
- មាសហ៊ែលស្តង់ដា

**ផលប្រយោជន៍ទទួលបាន :**

- ការថែទាំផ្ទាល់ខ្លួនមួយទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការ រស់នៅប្រចាំថ្ងៃ
- ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក
- ផែនការថែរទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីយើ
- វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់
- សមាជិកអាចទាក់ទងមក ២៤ម៉ោង

***To be eligibled for GAFC you must:***

- *live in subsidized or public housing*
- *age 22 years and older*
- *eligible for Masshealth Standard*

***Benefits you will get:***

- *personal care service in your home,*
- *Medication Managemant*
- *an individual care plan developed by a registered nurse and case manager*
- *ongoing monitoring of needs*
- *24-hour access to services*

## ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed for Lowell, Lynn, Revere, and Boston

ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន
បុគ្គលិកមានសណ្តានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវៈ
អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ

ដើម្បីចុះឈ្មោះសូមទាក់ទងមក
To register, please contact:
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

# ប្រវត្តិនៃព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប អកអំបុក និងសំពះព្រះខែ

**ភ្នំពេញៈ** ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក តែងតែប្រារព្ធក្នុងរយៈពេល៣ថ្ងៃ គឺពីថ្ងៃ១៤កើត ១៥កើត និងថ្ងៃ១រោច ខែកត្តិក នៅតាមទន្លេសាប ហើយសម្រាប់ឆ្នាំនេះ ត្រូវប្រារព្ធឡើងនៅថ្ងៃទី០២-០៣-០៤ ខែវិច្ឆិកា ឆ្នាំ២០១៦។

ដើម្បីអបអរព្រះរាជពិធីបុណ្យនេះ យើងសូមលើកយកនូវប្រវត្តិព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក មកផ្សាយជូនប្រិយមិត្តបានស្វែងយល់។

ខាងក្រោមនេះ ជាប្រវត្តិនៃព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ដែលដកស្រង់ចេញពី សៀវភៅ "ប្រវត្តិបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក" របស់គណៈកម្មាធិការ រៀបចំបុណ្យជាតិ អន្តរជាតិ។

ព្រះរាជពិធីបុណ្យ អុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក មានតាំងពីបូរមបុរាណយូរលង់មកហើយ ដែលមានចែងក្នុងឯកសាររបស់ប្រវត្តិវិទូបរទេស ក៏ដូចជាតាមសិលាចារឹកនៃប្រាសាទអង្គរ។

បុណ្យអុំទូកនេះ មានការបកស្រាយប្លែកៗគ្នាជាច្រើន ហើយពិធីធ្វើក៏ប្លែកៗគ្នាដែរ។

**កៈ** តាមសៀវភៅជ័យវរ្ម័នទី៧ មាននៅ





ក្នុងវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យពីដើមមានចែងថាៈ នៅក្នុងសម័យអង្គរនា គ.ស សតវត្សរ៍ទី១២ ប្រទេសកម្ពុជាមានសេចក្តីសុខក្សេមក្សាន្តរុងរឿងណាស់ ដោយព្រះបាទជ័យវរ្ម័នទី៧ ស្តេចយាងធ្វើសង្គ្រាមជើងទឹក ដើម្បីបង្ក្រាបពួកចាម ដោយកងទ័ពទូកជាចម្បាំងរំដោះក្រុងកម្ពុជាឱ្យរួចផុតស្រឡះពីខ្មាំងសត្រូវ (គ.ស ១១៧៧-១១៨១) រឿងចម្បាំងគ្រានោះ មានឆ្លាក់នៅលើជញ្ជាំងប្រាសាទបាយ័ន និងបន្ទាយឆ្មារ ។ ក្នុងចម្លាក់នោះ មានកងទ័ពទូកយ៉ាងច្រើនមហិមាដែលមានព្រះឆាយាល័ក្ខណ៍ ព្រះបាទជ័យវរ្ម័នទី៧ ប្រថាប់ឈរលើទីតាំងនាវាចម្បាំងដោយទ្រង់ធ្នូ និងដំបងយ៉ាងស្វាហាប់ក្នុងចំណោមកងទ័ពទូកទាំងឡាយ។

**ខៈ** ឯកសារល្បែងប្រណាំងទូករបស់ក្រុមជំនុំ ទំនៀមទម្លាប់លេខ១៩.០០៤ និពន្ធដោយលោក ថាច់ ប៉ែន ហៅ ប៉ាង អាចារ្យនៅពុទ្ធសាសនបណ្ឌិត្យរង ខេត្តឃ្លាំងកម្ពុជាក្រោម មានចែងថាៈ សម័យលង្វែក ព.ស២០៧១ គ.ស១៥២៨ ព្រះបាទអង្គចន្ទទី១ ទ្រង់តាំងពញាតាតងារជាស្ថិទ្ធិភូបាជាស្តេចក្រាញ់នៅកម្ពុជាក្រោម ស្រុកបាសាក់។ ស្តេចក្រាញ់នេះ បានចាត់របៀបរៀបចំការពារស្រុកមានដូចខាងក្រោមនេះ:

**ទាហានជើងទឹក ចែកជា៣ក្រុមៈ**

* ក្រុមទី១ ហៅទ័ពស្រួច ហាត់ច្បាំង និងទូកដែលមានទ្រង់ទ្រាយ ដូចទូកប្រណាំងយើងសព្វថ្ងៃ។

* ក្រុមទី២ ហៅទ័ពជំនួយ ហាត់ច្បាំង និងទូកចែវពីរជួរដែលមានទ្រង់ទ្រាយដូចទូកប្រណាំងយើងសព្វថ្ងៃ។

* ក្រុមទី៣ ហៅទ័ពបាសាក់ គឺទូកធំមានដំបូលមានចែវមានក្តោងមានទ្រង់ទ្រាយដូចទូកបាសាក់ ហៅទូកប៉ុកចាយតែរាងស្តួចវែងមានដំបូល តែមួយកាត់ខាងមុខឥតជញ្ជាំង។ល។ ជា

**តទៅទំព័រទី ១១**







## តមកពីទំព័រទី ១០ ប្រវត្តិនៃព្រះរាជពិធីបុណ្យអុំទូក...

ទូកដាក់ស្បៀងអាហារសម្រាប់កងទ័ព ។

របៀបបង្ហាត់ចម្បាំង "តាមទំនៀមស្តេចក្រាញ់កម្ពុជាក្រោម" ស្រេចលើមន្ត្រី៤ទិស "ចតុស្តម្ភ" ដែលមាននៅក្នុងឱវាទស្ទិទ្ធិភូបាល ស្តេចក្រាញ់គ្រប់ជំពូកដែលមានបញ្ញត្តិច្បាប់សម្រាប់ស្រុក ។ល។ កំណត់ថ្ងៃពេញបូណ៌មី ខែកត្តិក រដូវអកអំបុកនោះមន្ត្រី៤ទិសត្រូវកេណ្ឌទាហានទាំងជើងទឹក ជើងគោក "សមយុទ្ធ"១ថ្ងៃ១យប់រាល់ឆ្នាំ។ ចំណែកទាហានជើងទឹកឱ្យទៅប្រឡងឫទ្ធិឯទន្លេពាមកន្ទោរ ក្នុងខេត្តឃ្លាំង ត្បិតទីនោះមានទីប្រជុំទឹកគ្រប់ខេត្តទៅមកបានស្រួល។

តាមសៀវភៅ និងឯកសារជាប្រភពទាំងពីរខាងលើនេះ អាចសន្និដ្ឋានបានថា ប្រទេសកម្ពុជាសម័យបុរាណជាប្រទេសមានកងទ័ពជើងទឹកយ៉ាងខ្លាំងពូកែ និងមានពិធីហ្វឹកហ្វឺន ពិធីសមយុទ្ធកងទ័ពនេះ ជាប្រពៃណីជាប់រៀងរហូតមក ហើយអាចសន្និដ្ឋានបានទៀតថា ប្រទេសកម្ពុជាធ្វើពិធីនេះ រៀងរហូតមក គឺជាប់តំណមកពីសមយុទ្ធក្នុងសម័យបុរាណនេះឯង។





**ឥៈ** ឯកសារខ្លះបានសរសេរថា ព្រះរាជពិធីបុណ្យអុំទូក គឺជាបុណ្យប្រពៃណីជាតិដ៏ធំមួយរបស់ប្រទេសកម្ពុជា។ បុណ្យនេះមានរូបភាពប្រហាក់ប្រហែលនឹងបុណ្យប្រចាំរដូវរបស់ជនជាតិអឺរ៉ុប ដែលមានឈ្មោះថា សាំងហ្សង់ ដែលបច្ចុប្បន្នប្រារព្ធធ្វើនៅអឺរ៉ុបខាងជើង។ ប្រពៃណីខ្លះមានប្រវត្តិជាប់ទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងប្រវត្តិព្រះពុទ្ធជាម្ចាស់ ប៉ុន្តែការបកស្រាយមួយ ដែលអាចយកជាការគ្រប់គ្រាន់ គឺក្នុងបំណង "ដឹងគុណដល់ព្រះគង្គា និងព្រះធរណីដែលបានផ្តល់ដល់ជីវភាពរស់នៅ និងសុខុមាលភាពចំពោះទឹកដីវិញ ដែលយើងនាំគ្នាធ្វើឱ្យកករល្អក់"។

ការបកស្រាយចុងក្រោយនេះ គឺដូចគ្នាបេះបិទទៅនឹងទំនៀមទម្លាប់នៃព្រហ្មញ្ញសាសនា ហើយស្របនឹងស្ថានភាពភូមិសាស្ត្រជាក់ស្តែង និងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាកសិករយើង។ ព្រះរាជពិធីបុណ្យអុំទូកប្រព្រឹត្ត ទៅនៅថ្ងៃពេញបូណ៌មីខែកត្តិក ស្របទៅនឹងរដូវទឹកជំនន់ ដែលក្នុងរយៈពេលប៉ុន្មានខែហើយ បានធ្វើឱ្យបឹងបួរទាំងឡាយក្លាយទៅជាសមុទ្រដ៏ធំ ល្វឹងល្វើយ ហើយក៏បញ្ជាក់ទៀតថា ពេលនោះស្រូវ ក្នុងស្រែកំពុងតែទុំហើយ។ នៅពេលដែលទឹកទន្លេមេគង្គលិចជន់ "សីហា-វិច្ឆិកា" ទឹកជំនន់ដ៏សន្ធឹកសន្ធាប់បានចូលចាក់ស្រោចស្រពបឹង បួរតាមរយៈទន្លេសាប ដែលហូរពីត្បូងទៅជើង។ ដល់រដូវទឹកស្រកដែលចាប់ផ្តើមនៅខែវិច្ឆិកា ទឹកបឹងបួរហូរត្រឡប់តាមទន្លេសាបដដែលពីជើងមកត្បូងវិញ។

ជំនន់នៃទន្លេមេគង្គ ពិសេសជំនន់នៅតាមបឹងបួរមានប្រភពមកពីប្រទេសចិនដ៏សែនឆ្ងាយ បានផ្តល់នូវជីវភាពស្រែចម្ការនៅប្រទេសកម្ពុជា។ ដីល្បាប់ដែលបានដោយសារទឹកជំនន់នៃទន្លេបឹងបួរទាំងឡាយបានធ្វើឱ្យដីមានជីជាតិបង្កបាននូវធនធានសម្បូរបែបនៅក្នុងប្រទេសកម្ពុជា។ ដំណាំទាំងឡាយដែលកសិករ ធ្វើតាមចង្វាក់នៃទឹកស្រកបានផ្តល់នូវផលយ៉ាងច្រើនរាំងស្កាត់នូវគ្រោះទុរ្ភិក្ស និងផ្តល់នូវសុភមង្គល។

ដូច្នេះហើយបានជាដល់ រដូវទឹកស្រកបុរាណខ្មែរយើងកំណត់យកថ្ងៃពេញបូណ៌មី ខែកត្តិក ជារៀងរាល់ឆ្នាំ រៀបចំពិធីអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ដើម្បីសម្តែងមនោសញ្ចេតនាដឹងគុណទន្លេមេគង្គ និងទន្លេសាបដែលបានផ្តល់ជីជាតិយ៉ាងសំខាន់បម្រើវិស័យកសិកម្ម។ ព្រះរាជពិធីបុណ្យនេះតែង តែប្រារព្ធក្នុងរយៈ

**តទៅទំព័រទី ១៤**

CAMBRIDGE
A DIVISION OF PACE INDUSTRIES

យើងខ្ញុំផ្តល់ឲ្យនូវអាជីប, មិនមែនការងារទេ!



អតិថិជនរបស់យើងខ្ញុំ មានដូចជា Harley Davidson, Military, Starbucks និងមានជាច្រើនផ្សេងទៀត

ថ្មីៗកំពុងជ្រើសរើស

អ្នកកាន់ម៉ាស៊ីន, អ្នកតំឡើង និងអ្នកជួសជុលម៉ាស៊ីន

មិនតំរូវឲ្យមានបទពិសោធន៍! កំពុងស្វែងរកអ្នកបំរើការងារគ្រប់កម្រិតសម្រាប់វេន ១ និង ២។

នៅ Cambridge Division ដែលជាផ្នែកមួយរបស់ក្រុមហ៊ុន Pace Industries, យើងរីកចំរើនទាំងអស់គ្នា។ យើងបង្កើនទេពកោសល្យ។ យើងផ្តល់ឲ្យលោកអ្នកនូវឱកាសក្នុងការអភិវឌ្ឍន៍អាជីពដោយផ្អែកលើភាពខ្លាំង និងសក្តានុពលរបស់លោកអ្នក។ ក្រុមហ៊ុន Pace គឺជាទីកន្លែងដែលផ្តល់នូវគោលដៅនៃអាជីពមួយសម្រាប់អ្នកដែលមានទេពកោសល្យ, មានចំណាប់អារម្មណ៍ខ្លាំង, និងមានការចូលរួម ដើម្បីស្វែងរកនូវការឆ្នៃប្រឌិត, ការរីកចំរើន និងឱកាសដែលមានតែយើងជាអ្នកផ្តល់ឲ្យ។

យើងខ្ញុំផ្តល់នូវអត្ថប្រយោជន៍ដូចជា ការធានារ៉ាប់រងជីវិត, ធានារ៉ាប់រងពិការភាពរយៈពេលខ្លី, វិស្សមកាល, ការឈប់សម្រាក១០ថ្ងៃក្នុងមួយឆ្នាំដោយបានទទួលប្រាក់ឈ្នួល, ការឈប់សម្រាប់ទទួលបានប្រាក់ឈ្នួល ដោយកាត់ពីវិស្សមកាល និងការឈប់ពេលមានជំងឺ, ការធានាលើសុខភាព, ធ្មេញ និងភ្នែក, ការបង់រំលះថ្លៃសិក្សា, និងមានច្រើនផ្សេងទៀត។

សូមបោះឆ្នោតឲ្យលោកស្រី Noelle Creegan
សម្រាប់គណកម្មការសាលារៀនឡូវែល
-ផ្តោតចំពោះអនាគតរបស់យើង-



ខ្ញុំកំពុងបំរើការងារនៃគណកម្មការសាលារៀនដោយសារខ្ញុំជឿជាក់ថា អនាគតរបស់ក្រុងឡូវែល គឺផ្អែកទៅលើការវិនិយោគដែលយើងធ្វើទៅលើការអប់រំ។ បទពិសោធន៍នៃការអប់រំដ៏ល្អបំផុតនឹងបើកផ្លូវដល់សក្តានុពលរបស់ក្មេងៗ ហើយនឹងធានាឲ្យមានសហគមន៍ដែលសកម្ម និងខ្លាំង។

សូមជួយខ្ញុំដើម្បីគាំទ្រចំពោះអនាគតរបស់ក្រុងយើងសម្រាប់កូនចៅរបស់យើង ។ សូមបោះឆ្នោតឲ្យលោកស្រី Noelle Creegan សម្រាប់គណកម្មការសាលារៀនឡូវែល នៅថ្ងៃទី៧ ខែវិច្ឆិកា!

# “ប៉ូលិសអាកាដេមិ” បញ្ចេញនាយប៉ូលីសជំនាន់ទី២១

**ខ្មែរផុសស.រ.អា**

ឡូវែលៈ “ប៉ូលីសអូហ្វីស័រ”ថ្មី៤៥រូប ទើបនឹងបានប្រឡងចេញជាផ្លូវការនឹងប្រកបដោយជោគជ័យ កាលពីថ្ងៃទី៣វិច្ឆិការ២០១៧ នៅ “អាកាដេមីប៉ូលីសឡូវែល” ។

ខ្មែរផុស.ស.រ.អា.បានផ្សព្វផ្សាយដំណឹងជ្រើសរើសបេក្ខជន“នាយប៉ូលីស”ជូនសហគមន៍ខ្មែរ កាលពី២ឆ្នាំមុន -ក្នុងចំណោមនិស្សិត៦១នាក់ ដែលបានចុះឈ្មោះចូលសិក្សា ហើយបន្ទាប់ពីការសិក្សាយ៉ាងពេញទំហឹងចំនួន២៤ខែនៅ“អាកាដេមិ”



(ប៉ូលិសអាកាដេមី) ជំនាន់ទី២១

មកយុវបេក្ខជននាយប៉ូលីសទាំង៦១នាក់ មិន



គ្រួសារ ស ផែល   វីឈី ជាមួយម្តាយឪពុក



វីឈី ជាមួយនឹងបងប្អូនបង្កើត

បានទៅដល់ចុងបញ្ចប់នៃការសិក្សារបស់ខ្លួនទាំងអស់នោះទេ មានតែ៤៥នាក់ប៉ុណ្ណោះ បានប្រឡងជាប់នឹងប្រកាសជាផ្លូវការ ក្នុងនោះមាន “ប៉ូលីសអូហ្វស័រខ្មែរ”ចំនួន៤នាក់ -គួរឱ្យមានមោទនភាពដែលសហគមន៍ផ្តើមចាក់ឫសពិតប្រាកដជាខ្មែរអាមេរិកាំងពីឡូវែលនេះទៅហើយ ។

យើងបានជួបគ្រួសាររបស់“ប៉ូលីសអូហ្វីស័រខ្មែរ”ម្នាក់ដែលមានឈ្មោះ វីឈី ជុំ ដែលលោក ស ផែល ជា “ប្រូបេស្សុនអូហ្វីស័រ”នៅឡូវែលបានពីព័រនាយាយថា “យុវជនម្នាក់នេះ មានចំណូលចិត្តវិជ្ជាជីវជាប៉ូលីសនេះ តាំងតែពីនៅក្មេងមកម្ល៉េះ ហើយតែងតែមកសួរយោបល់ពីលោកពីការងារប៉ូលីសជាញឹកញយ... លោកក៏តែងតែណែនាំពីការងារក្រុងយុត្តិធម៌នឹងសន្តិសុខជាប្រចាំដែរ” ។ ឪពុកម្តាយរបស់ វីឈី គឺលោក ជេសុន នឹង លោកស្រី សារ៉េត ជុំ មានមោទនភាពណាស់ជំពោះជោគជ័យនៃការសិក្សារបស់កូនប្រុសម្នាក់ក្នុងចំណោមកូន៤នាក់ដែលាំដំណើរការប្រសើរប្រហាក់ប្រហែលគ្នានេះ ជាពិសេសលោកថា “ទំនងជាកូនលោកធ្លាប់ឃើញលោកធ្វើការជាបុគ្គលិកផ្នែកសន្តិសុខ ក៏ចូលចិត្តធ្វើតាមផ្លូវរបស់ឪពុកក៏មិនដឹង...” ។ ក្រុមគ្រួសារបានមកជួបជុំធ្វើការជប់លៀងអបអរពិធីប្រឡងជាប់របស់កូននៅផ្ទះ“ភីបឌី”យ៉ាងរីករាយ ៕






# សមាជិកក្រុមប្រឹក្សាក្រុងឡូវែលពិចារណាពីការហាមឃាត់ការចិញ្ចឹមឆ្កែពូជភីតប៊ូល



របងផ្ទះដែលក្មេងប្រុសអាយុ 7 ឆ្នាំម្នាក់ត្រូវបានសម្លាប់ដោយសារឆ្កែ

**ប្រែសម្រួលដោយខ្មែរផុស ស.រ.អា**

**ឡូវែល–** សមាជិកក្រុមប្រឹក្សាក្រុងឡូវែល គ្រោងនឹងអំពាវនាវឱ្យមានការហាមឃាត់ទូទាំងក្រុងឡូវែល ចំពោះការចិញ្ចឹមឆ្កែប្រភេទភីតប៊ូល បន្ទាប់ពីការស្លាប់របស់ក្មេងប្រុសអាយុ៧ឆ្នាំម្នាក់នៅឡូវែល។

បើតាមការចុះផ្សាយរបស់ព័ត៌ក្នុងស្រុកបានឱ្យដឹងថា មានការវាយប្រហាដោយឆ្កែពូជ ភីត ប៊ូលមកលើក្មេងប្រុសនោះបានកើតឡើងបន្ទាប់ពីមាន



ឆ្កែពូជ ភីត ប៊ូល

ក្មេងប្រុសនោះ កំពុងលេងបាល់ជាមួយនឹងក្មេងៗប្រហែលជាប្រាំមួយទៅប្រាំពីរផ្សេងទៀត ម៉ោងប្រហែល៦ល្ងាច។ នៅពេលកំពុងលេងបាល់បានចូលទៅក្នុងរបងផ្ទះនៅលើផ្លូវ Clare Street ដែលមានចិញ្ចឹមឆ្កែភីតប៊ូលចំនួនពីរក្បាលក្មេងប្រុសនោះក៏បានចូលទៅរើស ហើយត្រូវបានឆ្កែទាញខាំរហូតដល់ស្លាប់។

ដោយសារនៅក្រុងឡូវែលបច្ចុប្បន្ននេះ គឺមានប្រជាពលរដ្ឋរស់នៅច្រើន ដូច្នេះគ្មានកន្លែងណាដែលមានសុវត្ថិភាពក្នុងការរក្សាទុកប្រភេទឆ្កែភីតប៊ូលការអំពាវនាវនេះ គឺជាវិធានការចាំបាច់ដើម្បីរក្សានូវសុវត្ថភាពដល់ពលរដ្ឋ បើទោះបីជាការហាមឃាត់ការចិញ្ចឹមឆ្កែពូជភីតប៊ូលគឺជាបញ្ហាដ៏ចម្រូងចម្រាស់យ៉ាងណាក៏ដោយ។

សមាជិកក្រុមប្រឹក្សាក្រុងឡូវែលលោក រាតជីអ៊ីលឡូត បានកំពុងព្យាយាមធ្វើឱ្យមានកិច្ចប្រឹងប្រែងដើម្បីហាមឃាត់ចំពោះប្រភេទពូជឆ្កែភីតប៊ូល។ កាលពីឆ្នាំ២០១១ ច្បាប់ដែលបានស្នើឡើងដើម្បីដាក់កម្រិតលើការចិញ្ចឹមឆ្កែភីតប៊ូលត្រូវបានលើកឡើងម្តងរួចហើយ ប៉ុន្តែមិនបានសម្រេចនោះទេ ដោយត្រូវបានបដិសេដដោយសភានីតិបញ្ញត្តិនៅរដ្ឋម៉ាសាឈូសេត តែជំនួសមកវិញ ដោយរដ្ឋបានអនុម័តច្បាប់មួយដោយហាមឃាត់មិនឱ្យមានការបង្កើតច្បាប់ក្នុងការហាមមិនឱ្យមានការចិញ្ចឹមពូជឆ្កែគ្រាប់ប្រភេទណាមួយនោះទេ។ គួបញ្ជាកថានៅក្នុងឆ្នាំ២០១៤ មនុស្សចំនួន១៨៩នាក់ ត្រូវបានសម្រាកព្យាបាលនៅមន្ទីរពេទ្យដោយសារតែឆ្កែខាំនៅរដ្ឋម៉ាសាឈូសេត៕




# ខួបទី៣៣ ឆ្នាំនៃការបង្កើតសមាគមខ្មែរ CMAA នៅម៉ាសាឈូសេត

**ដោយ សុខាវ័ត្ថ កួយ**

**ឡូវែល**-កម្មវិធីការប្រារព្ធខួបទី៣៣ ឆ្នាំនៃការបង្កើតសមាគមខ្មែរត្រូវបានរៀបចំឡើងនៅថ្ងៃសៅរ៍ ទី៤ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅភោជនីយដ្ឋានសំពៅមានក្រុងឡូវែលដោយមានការចូលរួមពីសំណាក់ពីលោកអភិបាលក្រុងឡូវែល លោក អេត ខេនន័រដី, តំណាងរាស្ត្រខ្មែរ, តំណាងរាស្ត្រក្រុងឡូវែល, តំណាងក្រុមហ៊ុន និងអង្គការ និងប្រជាពលរដ្ឋខ្មែរប្រមាណជា៤០០នាក់។

ការរៀបចំនូវកម្មវិធីនេះ គឺផ្តោតជាសំខាន់ទៅលើការពង្រឹងសហគមនសម្រាប់គ្រាប់ជំនាន់ទាំងអស់។ នៅក្នុងកម្មវិធីនោះ មានការរាំរបាំប្រពៃណីពីសំណាក់ក្រុមរបាំអង្គរដានគ្រុប, ការផ្តល់រង្វាន់ដល់អ្នកមានស្នាដៃក្នុងការបំរើសហគមន៏, ការចាក់វីដូអូបង្ហាញពីសកម្មភាពការងារ និងការសម្រេចបានរបស់សមាគម, កម្មវិធីរៃអង្គាសថវិការ, និងកម្មវិធីអាហាពេលល្ងាច និងការរាំកំសាន្ត។

គួបញ្ជាក់ថា សមាគមខ្មែរនៅឡូវែល ផ្តល់សេវាមួយចំនួនដូចជាជំនួយផ្នែកដាក់ពាក្យចូលសញ្ជាតិអាមេរិក, សេវាបកប្រែភាសានៅនឹងកន្លែង និងសិក្ខាសាលាច្រើនវគ្គទៀតពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុ និងការអប់រំ។ ជាងនេះទៅទៀត CMAA ក៏បានបង្កើតនូវកម្មវិធីជាច្រើនទៀតដូចជាកម្មវិធីតារាកំពុងរះ, កម្មវិធីភាពជាអ្នកដឹកនាំជំនាញរបស់យុវជន និងកម្មវិធីភាពជាសហគ្រិនសម្រាប់អ្នកទាំងអស់គ្នា។



សម្រាប់រយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ សមាគមខ្មែCMAA បានផ្តល់សេវាជូនដល់ពលរដ្ឋខ្មែរដែលបានមកទទួលសេវាដោយមិនមានការណាត់ជួបជាមុនចំនួន៣០០០នាក់ ។ បេសកកម្មរបស់ CMAA គឺដើម្បីលើកកម្ពស់គុណភាពជីវិតសម្រាប់ពលរដ្ឋខ្មែរអាមេរិកនិងជនជាតិភាគតិចដទៃទៀតនិងពលរដ្ឋដែលខ្វះខាតខាងសេដ្ឋកិច្ចនៅទីក្រុងឡូវែលតាមរយៈកម្មវិធីអប់រំ, វប្បធមិ, សេដ្ឋកិច្ច និងសង្គម ៕







## តមកទំព័រទី ១១ ប្រវត្តិនៃព្រះរាជពិធីបុណ្យអុំទូក...

ពេល៣ថ្ងៃគឺ ពីថ្ងៃ១៤កើត ១៥កើត និងថ្ងៃ១រោចខែកត្តិក នៅតាមទន្លេសាប។

**ប្រភពពិធីបណ្តែតប្រទីប**

**ក៖** គម្ពីទាថាវង្ស ភាសាបាលីមានចែងថា ព្រះចង្កូមកែវទាំង៤ នៃព្រះសម្មាសម្ពុទ្ធប្រតិស្ឋាន នៅទីទាំង៤ គឺ:

**ទី១:** នៅត្រៃត្រឹង្សសួគិទី២: នៅភពនាគទី៣: នៅស្រុកគន្ធាទី៤: នៅទន្តបុរៈកលិង្គរដ្ឋ

**ខ៖** ភាណវារៈបាលី ត្រង់ពុទ្ធនមក្ការគាថា មានចែងថាស្នាមព្រះបាទព្រះសាម្មាសាម្ពុទ ប្រតិស្ឋាន នៅទីតាំង៥គឺ

**ទី១:** នៅសុវណ្ណមាលិបរពតទី២: នៅសុវណ្ណបរពតទី៣: នៅសុមនកូដបរពត

**ទី៤:** នៅយោនកបុរី

**ទី៥:** នៅស្ទឹងនម្មទា

**គ៖** ពាក្យសសើរព្រះបាទ "យស្សបាទេ" ទាំងបាលី ទាំងស្រមោលមានចែងថា ព្រះបាទសម្មាសម្ពុទ្ធប្រតិស្ឋាននៅទីទាំង៥ ដូចនៅក្នុងភាណរៈដែរ។

ដោយហេតុមានគម្ពីរដីកាជាប្រភពយ៉ាងនេះ បានជាពុទ្ធបរិស័ទខេមរជាតិតែងធ្វើពិធីបណ្តែតប្រទីបនៅយប់ពេញបូរមីខែអស្សុជដែលក្រោយមកគេប្រារព្ធពិធីបណ្តែតប្រទីប នៅយប់ ១៤-១៥កើត និង១រោជ ខែកត្តិក បូជាចំពោះព្រះចង្កូមកែវពិភពនាគព្រះពុទ្ធបានទៅស្ទឹងនម្មទា និងនៅទីឯទៀតដូចជាពោលខាងលើ



ហើយដោយជឿថា ជាការកុសលយ៉ាងធំបានផលយ៉ាងប្រសើរ ដើម្បីសុខចំរើនរុងរឿងដល់ខ្លួនដល់ប្រជាជន និងប្រទេសជាតិ។

**ប្រភពនៃពិធីសំពះព្រះខែ អកអំបុក**

តាមគម្ពីរបរមត្ថទីបនី អដ្ឋកថា ចរិយាបិដក ភាសាបាលីមានចែងថា ក្នុងដើមីភទ្ទបក្បនេះ ព្រះបរមពោធិសត្វនៃយើងទ្រង់យោនយកកំណើតជាសសបណ្ឌិត "កំណើតជាទន្សាយ"។ នៅថ្ងៃពេញបរមីមួយសសបណ្ឌិតបានអធិដ្ឋានឧបោសថសីល ហើយឧទ្ទិសមំសៈជាទានបរមត្ថបារមី ដើម្បីបំពេញពោធិ៍សម្ភារឱ្យបានត្រាស់ជាព្រះពុទ្ធ។ ព្រះឥន្ទ្រទ្រង់ជ្រាបហេតុការណ៏នោះក៏ទ្រង់ក្រឡាខ្លួន ជាព្រាហ្មណ៏ចាស់មកសុំសបណ្ឌិតជាអាហារ សសបណ្ឌិតពោធិសត្វ បានឱ្យព្រានចាស់នោះបង្កាត់ភ្លើងភ្នក់ ហើយក្នុងពេលដែលភ្លើងកំពុងឆេះសន្ធោសន្ធៅសបណ្ឌិតក៏រលាស់ខ្លួន៣ដង ដើម្បីឱ្យសត្វល្អិតដែលជាប់នៅនិងរោមជ្រុះចេញរួច ក៏លោតចូលទៅក្នុងភ្នក់ភ្លើងភ្លាម។ អស្ចារ្យណាស់ភ្លើងនោះពុំបានឆេះសសបណ្ឌិតសោះឥន្ទ្រព្រាហ្មណ៏បានស្ទុះទៅពព្រះពោធិសត្វឡើងទៅដល់មណ្ឌលព្រះចន្ទ្រ ហើយទ្រង់យកម្នាងសិលាគូររូបទន្សាយ ហើយឥន្ទ្រព្រាហ្មណ៏អធិដ្ឋានថា សូមឱ្យរូបទន្សាយពោធិសត្វដែលខ្ញុំគូរនេះ នៅជាប់រហូតដល់ទីបំផុតកប្ប។

ដោយអនុភាពទានបរមត្ថបារមីនៃព្រះពោធិសត្វផង និងសេចក្តីអធិដ្ឋានរបស់ព្រះឥន្ទ្រផង រូបទន្សាយក៏ឃើញប្រាកដក្នុងមណ្ឌលព្រះចន្ទ្រដរាបដល់សព្វថ្ងៃ។

ដោយជឿតាមរឿងនេះហើយ បានជានៅវេលាយប់ពេញបូរមី ខែកត្តិករៀងរាល់ឆ្នាំខ្មែរយើងយកចំណី មានអំបុក និងចេកជាដើម មកបូជាព្រះចន្ទ្រ ហៅថាពិធីសំពះព្រះខែអកអំបុក៕

# Health Connector ផ្សព្វផ្សាយពីកម្មវិធីបើកការទទួលចុះឈ្មោះធានារ៉ាប់រងសុខភាពឆ្នាំ ២០១៨

**ដោយខ្មែរផុសស.រ.អា**

ឡូវែល-សម្រាប់ឆ្នាំ២០១៨Massachusetts Health Connector បានបើកយុទ្ធនាការចុះទៅតាមមូលដ្ឋានជាច្រើនកន្លែងក្នុងគោលបំណងដើម្បីផ្សព្វផ្សាយ និងអប់រំពីកម្មវិធីចុះឈ្មោះធានារ៉ាប់រងសុខភាពរបស់ខ្លួន ជាពិសេសនៅតាមបណ្តាក្រុងមួយចំនួនដែលមានអាត្រាពលរដ្ឋមិនមានធានារ៉ាប់រងខ្ពស់។

តាមព័ត៌មានដែលខ្មែរផុសបានទទួលនោះគឺថាកាលពីថ្ងៃពុធ ទី២៥ ខែតុលា ឆ្នាំ២០១៧ បុគ្គលិកសម្របសម្រួលរបស់ Health Connector បានចុះជួបជាមួយក្រុមហ៊ុន និងហាងជាច្រើននៅក្នុងក្រុងឡូវែល ក្នុងនោះរួមមានក្រុមហ៊ុន Amara Boutique & Service និងភោជនីយដ្ឋានកូលាបក្រហមដើម្បីដាក់តាំងនូវផ្ទាំងផ្សព្វផ្សាយដោយមានភាសាចំរុះសម្រាប់ជំរុញយុទ្ធនាការបើកការចុះឈ្មោះធានារ៉ាប់រងឆ្នាំ២០១៨។

លោកស្រី លូអ៊ីស គូធារីស ជានាយកប្រត្តិបត្តិរបស់ Health Connector បានមានប្រសាសន៍ថា "រដ្ឋម៉ាសាជូសេតនៅតែបន្តប្តេជ្ញាចំពោះចក្ខុវិស័យនៃការគ្របដណ្តប់រ៉ាសេ ធានារ៉ាប់រងឱ្យបានទូលំទំលាយ, ដូច្នេះយើងចង់ចុះទៅសហគមន៍ ដើម្បីឱ្យប្រជាពលរដ្ឋដឹងអំពីការចាប់ផ្តើមការចុះឈ្មោះការធានារ៉ាបរង"។ លោកស្រីក៏បានថែមទៀតថា ការចុះតាមសហគមន៍នេះ គឺចង់ឱ្យពលរដ្ឋដឹងថា ពួកគេមានជម្រើសនៃការធានារ៉ាប់រងយ៉ាងទូលំទូលាយនៅក្នុងរដ្ឋម៉ាសាជូសេតដោយរួមមានទាំងការធានារ៉ាប់រងដែលមានការជួយឧបត្ថម្ភធនពីរដ្ឋ និងគម្រោងចំនួន៥២ដើម្បីជ្រើសរើស។




ប្រភពដដែលក៏បានឱ្យដឹងថា ដំណើរការនៃការបើកទទួលចុះឈ្មោះធានារ៉ាប់រងរបស់ Health Connector គឺចាប់ ពីខែវិច្ឆិកា ឆ្នាំ២០១៧ រហូតដល់ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៨។ គួបញ្ជាក់ថា យុទ្ធនាការនេះ មិនត្រឹមតែចុះទៅតាមសហគមន៍សម្រាប់ប្រជាពលរដ្ឋទូទៅប៉ុណ្ណោះទេ Health Connector ក៏បានធ្វើការផ្សព្វផ្សាយនៅតាមសាលារៀនសម្រាប់សិស្សានុសិស្ស ផងដែរ៕



# គណៈកម្មការពិសេសៈ រដ្ឋម៉ាសាឈូសេត គួរផ្លាស់ប្តូរស្តង់ដាម៉ោងជាអាត្លង់ទិចដោយមានលក្ខខណ្ឌមួយចំនួន

**ដោយ សុខារ័ត្ន កួយ**

ប៊ូស្តុន់ -ការផ្លាស់ប្តូរម៉ោងត្រូវបានកើតមាននៅតាមរដ្ឋមួយចំនួននៅសហរដ្ឋអាមេរិកជាពិសេសការផ្លាស់ប្តូរក្នុងមួយឆ្នាំចំនួនពីរដង នៅចន្លោះនិទាឃរដូវរីររដូវផ្ការីក និងរដូវឈើជ្រុះស្លឹក។ កាលពីឆ្នាំ២០១៦ រដ្ឋម៉ាសាឈូសេត បានកំណត់ម៉ោងនាឡិការលើស១ម៉ោង ដោយចាប់ពីខែវិច្ឆិកា រហូតដល់ខែកុម្ភៈ ហើយខែមិនា រហូតដល់ខែកញ្ញាបានកំណត់ម៉ោងត្រឡបថយក្រោយ១ម៉ោងវិញតាមធម្មតា។

សម្រាប់ឆ្នាំ២០១៧ គណៈកម្មការពិសេសកំណត់ស្តង់ដាម៉ោងនៃរដ្ឋម៉ាសាឈូសេតដែលបានបង្កើតឡើយកាលពីឆ្នាំមុខ និងមានសមាជិកចំនួន១១រូបបានបោះឆ្នោតកាលពីថ្ងៃពុធ ទី១ ខែវិច្ឆិកានេះ បានអនុម័តទៅលើរបាយការណ៍ស្តីពីការកំណត់ស្តង់ដាម៉ោង ដោយលទ្ធផលនៃរបាយការណ៍នេះ បានណែនាំឱ្យរដ្ឋម៉ាសាឈូសេតធ្វើការផ្លាស់ប្តូរម៉ោងពីម៉ោងអ៊ីសស្ទូន (Eastern) ទៅជាម៉ោងអាត្លង់ទិច (Atlantic) ដែលជាផលប្រយោជន៏សម្រាប់រដ្ឋទាំងមូលតែផ្អែកលើលក្ខខណ្ឌមួយចំនួន។

មុននឹងអនុម័តទៅលើរបាយការណ៍គណៈកម្មការពិសេសនេះ បានចំណាយពេលជាច្រើនខែដើម្បីសិក្សាទៅលើគុណសម្បត្តិ និងគុណវបត្តិ


កិច្ចប្រជុំគណៈកម្មការពិសេសស្តីពីការផ្លាស់ប្តូរម៉ោងនៃរដ្ឋម៉ាសាឈូសេត កាលពីថ្ងៃពុធ ទី១ ខែវិច្ឆិកា ឆ្នាំ ២០១៧ ដឹកនាំដោយលោកស្រី អ៊ីលីន ដូនូឡ

នៃការបង្កើតឱ្យមានការផ្លាស់ប្តូរពេលវេលាដើម្បីសន្សំពេលថ្ងៃឱ្យច្រើនពេញមួយឆ្នាំ។ តាមរយៈការណែនាំនៅក្នុងការសិក្សានេះ ការប្រើប្រាស់ម៉ោងអាត្លង់ទិច នឹងលុបបំបាត់មិនឱ្យមានការអនុវត្តកំណត់ម៉ោងលើសរីទៅមុខនិងថយក្រោយ ឬត្រឡប់មកវិញពីរដងជារៀងរាល់ឆ្នាំដែលធ្លាប់ធ្វើពីមុននោះទៀតឡើយ។ ជំនួសមកវិញ វានាំមកនូវម៉ោងបន្ថែមសម្រាប់ពេលវេលាថ្ងៃត្រង់ច្រើនជាងមុននៅរដូវរងា ឬសិសិររដូវ។

បើតាមលោកស្រី អ៊ីលីន ដូនូខ្យូ ដែលជាសមាជិកព្រឹត្តសភា និងជាប្រធានគណៈកម្មការពិសេសនេះ បានមានប្រសាសន៏បន្ទាប់ពីកិច្ចប្រជុំថា "យើងមិនគួរធ្វើការផ្លាស់ប្តូរម៉ោងតែឯងសម្រាប់រដ្ឋម៉ាសាឈូសេតនោះទេ។ យើងនឹងរីករាយទៅនឹងការផ្លាសប្តូរនេះ ប្រសិនបើយើងមានរដ្ឋភាគឥសាន្ត ដូចជា ម៉ែន, ញូហ៊ាមស័រ និងរដ្ឋអាយលិន និងក្រុងញ៉ូយកធ្វើការផ្លាស់ប្តូរព្រមគ្នាដែរនោះ"។ លោកស្រីបានបញ្ជាក់ទៀតថា ការអនុម័តលើរបាយការណ៍នេះ គឺគ្រាន់តែជាការចាប់ផ្តើមនៃការពិភាក្សាប៉ុណ្ណោះ មិនទាន់បញ្ចប់នៅឡើយនោះទេ។

យោងតាមរបាយការណ៏ដដែរបានបង្ហាញថា ការផ្លាស់ប្តូរទៅប្រើប្រាស់ម៉ោងពេលវេលាម៉ោងអាត្លង់ទិច គឺអាស្រ័យលើលក្ខខណ្ឌ៣ចំណុចសំខាន់ គឺទី១ ប្រតិកម្មនៃតំបន់ មានន័យថា ការផ្លាស់ប្តូរអាចកើតមានឡើង ដរ៉ាបណាភាគច្រើននៃរដ្ឋភាគឥសាន្ត (ប្រសិនជាអាចរួមទាំងក្រុងញ៉ូយក) យល់ព្រមធ្វើការផ្លាស់ប្តូរផងដែរ។ ចំណុចទី២ គឺការចាប់ផ្តើមចូលរៀនរបស់សិស្សមានការយឺតជាងមុន មានន័យថា រាល់ការផ្លាស់ប្តូរណាមួយ គួរតែត្រូវធ្វើដោយស្របទៅតាមស្តង់ដាទូទាំងរដ្ឋទាំងអស់សម្រាប់ការពន្យាពេលវេលាក្នុងការចាប់ផ្តើមចូលរៀនរបស់សិស្សដើម្បីកាត់បន្ថយបញ្ហាសុវត្ថិភាពនិងធ្វើឱ្យប្រសើរឡើងនូវលទ្ធផលសិក្សា, សុខភាព និងសុខុមាលភាពរបស់សិស្ស។ ចំណុចទី ៣នោះគឺថា ការផ្លាស់ប្តូរម៉ោងពេលណាមួយត្រូវតែធ្វើឡើងស្រមទៅតាមការយល់ដឹងរបស់សាធារណៈជនអំពីដំណើរការនៃការផ្លាស់ប្តូរម៉ោងពេលឆ្ពោះទៅរកការរសន្សំពេលវេលាពេលថ្ងៃនោះ។

ផ្អែកតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវដោយអ្នកជំនាញបានរកឃើញថា អត្ថប្រយោជន៏នៃការផ្លាស់ប្តូរម៉ោងអាត្លង់ទិច គឺរួមមានការសន្សំការប្រើប្រាស់ថាមពលអគ្គិសនី, ការជំរុញឱ្យមានដំណើរការលក់ដូរសម្រាប់ហាងលក់រាយ, កាត់បន្ថយបទល្មើស, គ្រោះថ្នាក់ចរាចរតិចតួច និងកាត់បន្ថយផលប៉ះពាល់ផ្នែកផ្លូវចិត្តតាមរដូវកាលរបស់ពលរដ្ឋ។




ទន្ទឹមនឹងនេះ របាយការណ៏ដដែរ ក៏បានទទួលស្គាល់ពីលទ្ធភាពនៃការងផលប៉ះពាល់ចំពោះសក្តានុពលមួយចំនួនរបស់រដ្ឋផងដែរដូចជាខាងផ្នែកដឹកជញ្ជូន, ពេលវេលានៃការផ្សព្វផ្សាយ និងព្រឹត្តិការណ៏កីឡានានាជាដើម។

គួរបញ្ជាក់ថារបាយការណ៏ដែលបានលើកឡើងពីអត្ថប្រយោជន៏ និងផលប៉ះពាល់នៃការផ្លាស់ប្តូរស្តង់ដាម៉ោងនៃរដ្ឋម៉ាសាឈូសេត នឹងត្រូវបញ្ជូនទៅកាន់រដ្ឋសភាបន្តបន្ទាប់ពីត្រូវបានអនុម័តដោយគណៈកម្មការពិសេសនេះ៕












**NOTICE OF PUBLIC REVIEW AND COMMENT PERIOD AND PUBLIC MEETING ANNOUNCEMENT**

The Northern Middlesex Metropolitan Planning Organization (NMMPO) has releasedAmendment 1 to the FFY 2018-2022 Transportation Improvement Program (TIP) for a 21-day public review and comment period ending on November 17, 2017.The amendment includes funding for Lowell Regional Transit Authority replacement minibuses and the programming of a deck replacement project on the Lowell Connector over Industrial Avenue. Please note the TIP contains the program of projects for the LRTA.

A copy of thedraft amendment is available online at www.nmcog.org..A public meeting on the draft documents will be held on November 9, 2017, 5:30 PM, at the Northern Middlesex Council of Governments (NMCOG) office, 40 Church St., Suite 200, Lowell, MA. You may also submit comments by phone at (978) 454-8021, ext 121, or by email: jhoward@nmcog.org. If preferred, comments may be mailed to the above address. The NMMPO's public participation process satisfies the LRTA's public participation requirements for the program of projects.

**សេចក្តីជូនដំណឹងស្តីពីរយៈពេលនៃការពិនិត្យ និងការសម្តែងមតិជាសាធារណៈ និងកិច្ចប្រជុំជាសាធារណៈ**

អង្គភាពរៀបចំក្រុង ន័សធន ម៉ីដូលសិច ហៅកាត់ NMMPO បានធ្វើការប្រកាសពីការធ្វើវិសោធនកម្មលើកទី១ ចំពោះគម្រោងកម្មវិធីលើកកម្ពស់ការដឹកជញ្ជូន (TIP)FFY ឆ្នាំ២០១៨-២០២២ ដើម្បីឱ្យមានការពិនិត្យ និងការសម្តែងមតិយោបលជាសាធារណៈ រយៈពេល២១ថ្ងៃ ដោយត្រូវបញ្ចប់នៅថ្ងៃទី ១៧ ខែវិច្ឆកា ឆ្នាំ២០១៧។ ការធ្វើវិសោធនកម្មនេះ រួមមានការផ្តល់មូលនិធិដើម្បីទិញឡានក្រុងសម្រាប់អាជ្ញាធរដឹកជញ្ជូនថ្នាក់តំបន់ឡូវែល (LRTA) និងកម្មវិធីគម្រោងជួសជុលស្ពាននៅចំណុច Lowell Connector លើមហាវិថី Industry Avenue។ គួបញ្ជាក់ថាគម្រោងកម្មវិធីលើកកម្ពស់ការដឹកជញ្ជូន (TIP) រួមមានគម្រោងកម្មវិធីរបស់អាជ្ញាធរដឹកជញ្ជូនតំបន់ឡូវែល (LRTA) ផងដែរ។

ច្បាប់ចម្លងស្តីពីពង្រៀងវិសោធនកម្មនេះមាននៅអនឡាញ www.nmcog.org។ កិច្ចប្រជុំជាសាធារណៈដើម្បីពិភាក្សាពីពង្រៀងវិសោធនកម្មនេះ នឹងធ្វើការរៀបចំឡើងនៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅម៉ោង ៥:៣០ល្ងាច នៅការិយាល័យក្រុមប្រឹក្សាភិបាល ន័សធន ម៉ីដូលសិច ដែលមានទីតាំងស្ថិតនៅផ្លូវ 40Church Street, Suite 200, Lowell, MA។ លោកអ្នកក៏អាចផ្តល់ព័តិមានពីមតិយោបលរបស់លោកអ្នកតាមរយៈលេខទូរស័ព្ទ សព្ទ (978) 454-8021, ext 121 ឬអ៊ីមែលទៅកាន់ jhoward@nmcog.org។ ប្រសើនបើចង់ផ្ញើជាសំបុត្រ, លោកអ្នកអាចផ្ញើមត្តិយោបលរបស់លោកអ្នកមកកាន់អាស័យដ្ឋានខាងលើ។

ដំណើរការនៃការរៀបចំឱ្យមានការចូលរួមជាសាធាណៈរបស់អង្គភាពរៀបចំក្រុងនេះ គឺវាស្របទៅនឹងតំរូវការឱ្យមានការចូលរួមជាសាធាណៈរបស់អាជ្ញាធរ LRTA សម្រាប់កម្មវិធីនៃគម្រោងជាច្រើន។




**នាអំឡុងឆ្នាំ១៩៥០-៦០ តើមានអ្វីកើតឡើងនៅក្នុងជីវភាពគ្រួសារខ្មែរ!**

ដោយ ខ្មែរផុសស.រ.អា

តពីលេខមុន

ម៉ោង៧ចៅប៉ុនត្រៀមខ្លួនជាស្រេច ដើម្បីទៅបង្ហាញខ្លួននៅចំពោះសមត្ថកិច្ចយោធាដែរ ។ ធ្វើការងារនេះចប់ចៅប៉ុនមានពេលមួយខែសម្រាប់ដោះរលេងជាមួយប្អូន ។ ឱកាសរីករាយជាមួយ ចៅពិន មានមួយខែមែនតែមិនយូរទេ ពីព្រោះពេលវេលាល្អធ្វើឱ្យពួកគេភ្លេចខ្លួនថាថ្ងៃត្រឡប់ទៅកំពុងចាមវិញនោះ កាន់តែខិតនោះទេ, បន្ថែមពីនោះក៏មានសិស្សកុមារយោធាដែលចេញទៅរៀនពីបន្ទាយតែមួយឈ្មោះ ព្រឿង គេអាយុធំជាងចៅប៉ុនបន្តិច ក៏បានស្គាត់មកជួបគ្នា រឹតតែធ្វើឱ្យបរិយាកាសរឹតតែអ៊ូអរខ្លាំងឡើងដែរ ។

នៅមុនដាច់ខែមួយអាទិត្យចៅពិនបាន ខោខ្លីកាគី១ ខោខ្លីពណ៌ខៀវ២ នឹងអាវសដៃខ្លី២ ដែលម្តាយដេរឱ្យសម្រាប់ស្លៀកពាក់ទៅចូលរៀនបន្ថែមពីលើនេះ ក៏មានកាតាបពណ៌លឿងដែលមានខ្សែដៃស្ពាយបកការជ័រលុបនឹងសៀវភៅសរសេរ២ក្បាលផង, លើកនេះចៅប៉ុនជាអ្នកជូនប្អូនទៅផ្ទះបងស្រីដែលនៅឯផ្សារម្តង ដោយឪពុកឱ្យជិះរ៉ឺម៉កពាក់ជាមួយនឹងមិត្តកុមារយោធាបងព្រឿង ទៅជាមួយផង។ អ្នកបងស្រីមានសេចក្តីរីករាយនឹងទទួលប្អូនជាពន្លឹក... ទាំងពនាក់ នាំគ្នាដើរលេងនៅផ្សារអស់ចិត្តល្ងាចឡើងទើបចៅប៉ុននឹងបងព្រឿងត្រឡប់មកបន្ទាយវិញ ដោយទុកឱ្យចៅពិននៅទីនោះ យ៉ាងសោះកក្រស់ ។

មិនយូរប៉ុន្មានក៏ដល់ពេលចៅប៉ុននឹងបងព្រឿងចេញដំណើរតានរថយន្តឈ្នួលពីក្រោយផ្សារកំពុងស្ពឺត្រឡប់ទៅរកបន្ទាយខ្លួនបន្ទាប់ពីទៅបង្ហាញមុខនៅការិយាល័យយោធាដដែលថាខ្លួននឹងត្រឡប់ទៅកាន់កងឯកភាពរបស់ខ្លួនឯកំពុងចាមនៅថ្ងៃស្អែកវិញហើយ ។

ចៅពិនក៏ដល់ពេលត្រូវចូលទៅសាលារៀនហើយដែរ, នារៀងរាល់ព្រឹកកូនក្មេងបានទៅរៀនគ្រប់គ្នានៅសាលារៀនដែលមានផ្លាកសញ្ញាសរសេរជាអក្សរខ្មែរជំនួសឱ្យអក្សរបារាំងដែលធ្លាប់ឃើញពីពេលមុនមក -គេឈរតម្រង់ជួរមានលោកគ្រូ អ្នកគ្រូឈរក្បែរសិស្សនៃថ្នាក់របស់ខ្លួននាំគ្នាច្រៀងបទ"នគររាជ"៣បទ ដើម្បីគោរពទង់ជាតិជាមួយគ្នានោះ ក៏មានសិស្សស្រីម្នាក់នឹងសិស្សប្រុសម្នាក់ជាអ្នកឡើងទាញខ្សែរបង្ហូតទង់ជាតិខ្មែរឡើងទៅលើបង្គោលសខ្ពស់មួយដែលស្ថិតនៅកណ្តាលសួនច្បារមានរាងជារង្វង់មូលប្រកបដោយផ្ការចម្រុះពណ៌ដ៏ស្អាត Estrade ណាស់។ គោរពទង់ជាតិចប់អ្នកគ្រូនាំកូនសិស្សគាត់មួយក្រុមៗដើរជាជួរតម្រង់ទៅថ្នាក់រៀងៗខ្លួន ជាឱកាសដែលចៅពិនចូលចិត្តធ្វើតាម ដូចកាលនៅក្នុងបន្ទាយដែលកងពលនាំគ្នាដើរជាក្បួនដ៏មានសណ្តាប់ធ្នាប់តាមបញ្ជាមេកងរបស់ខ្លួន




ផែនទីកម្ពុជាពេលបារាំងទើបមកដល់

ចុងបញ្ចប់បែរជាធ្វើឱ្យទឹកព្រួចទៅដល់ម្តាយនឹងឪពុករបស់ខ្លួនដែលនឹងចេញចាកទៅឆ្ងាយនៅប៉ុន្មានសប្តាហ៍ខាងមុខនេះហើយ ។

អ្នកគ្រូ ម៉ាន់យ៉ុន មានតុនឹងកៅអីរបស់គាត់ដាក់បន្ទុបលើក្តារលើកឱ្យខ្ពស់របស់គាត់ គេហៅថា "អេស្រ្តាដ Estrade" សម្រាប់មើលឱ្យឃើញសិស្សរហូតដល់អ្នកដែលអង្គុយនៅក្រោយបង្អស់បាននៅក្បែរគាត់នឹងពីមុខកូនសិស្សសម្រាប់គាត់សរសេរនឹងពន្យល់សិស្សរបស់គាត់ ។ គាត់និយាយលេងច្រើនជូនកាលក៏និយាយរឿងឱ្យស្តាប់ជួនកាលក៏ឱ្យសិស្សថា តាមគាត់ឱ្យព្រមៗគ្នាឮឱ្យខ្ទរដល់ថ្នាក់គេឯទៀតផង ជួនកាលទៀត អ្នកគ្រូតាំងជាសំនួរដល់សិស្ស ហើយដើម្បីឆ្លើយចៅពិនត្រូវលើកដៃឡើងឱ្យអ្នកគ្រូហៅឈ្មោះ ដើម្បីឆ្លើយហើយពេលខ្លះនោះ អ្នកគ្រូហៅអ្នកឯទៀតឱ្យឆ្លើយតែមិនព្រមហៅចៅពិនសោះធ្វើឱ្យចៅពិនខឹងធ្វើមុខក្រញូវដាក់អុកក្តិតអង្គុយ, ឃើញដូច្នោះអ្នកគ្រូក៏ធ្វើជាដល់វេនសួរសិស្សមុខក្រញូវរបស់ខ្លួនជំនួសដោយពាក្យលួងលោមណឹងឬរបរិយាកាសផង។ មានពេលខ្លះទៀត ដល់វេនអ្នកគ្រូមុខក្រញូវម្តងវិញ ដោយមានសិស្សដែលមិនព្រមធ្វើតាមការប្រៀនប្រដៅ ហើយធ្វើខុសដដែលៗ ឬក៏ធ្វើផ្តើនអ្នកគ្រូពេលនោះអ្នកគ្រូក៏ដករំពាត់ផ្តៅដេញមកបញ្ជាឱ្យសិស្សលាដៃឱ្យគាត់វាយបាតដៃ១រំពាត់ទៅដល់៣រំពាត់ទៅតាមទោសដែលធ្ងន់ឬស្រាលទោះជាវាយមិនឈឺក្តី ក៏ជាឱកាសដ៏គួរឱ្យខ្លាចអ្នកគ្រូណាស់ ពីព្រោះវាធ្វើឱ្យខ្មាសដល់សិស្សឯទៀតៗជាខ្លាំងណាស់ដែរ ។

អ្នកគ្រូក៏មានកូនស្រីម្នាក់ដែរ រៀននៅថ្នាក់មួយផ្សេងនៅឆ្ងាយពីគ្នាបន្តិចមែនតែកូនអ្នកគ្រូតែងរត់មករកម្តាយជារឿយៗ ជាពិសេសនៅពេលចេញលេងដែលមាន២ដងក្នុងពេលព្រឹក១ដងនៅពេលល្ងាចអ្នកគ្រូតែងមានអ្វីហុចឱ្យកូនជានិច្ចដូចជានុំចំណើសម្រន់ពោះ ចំណែកឯកូនសិស្សឯទៀត ដែលមានប្រាក់កាសក្នុងហោប៉ាវ តែងរត់ទៅទិញចំណីចំណុកដូចជា នំុក្រូចចេកចៀន ឬនំុពុម្ព ឬក៏សណ្តែកដីស្ងោ ឬក៏ស្ករគ្រាប់... ដែលគេលក់នៅក្រៅរបងតាមបន្លោះដែលគេវែកលួសបន្លាចេញ កុំឱ្យមុតដៃ។ សិស្សខ្លះទៀតរត់លេងបន្លែងគ្នាខ្ទាត់ខ្វែង ចំណែកលោកគ្រូអ្នកគ្រូ ក៏ស្វែងរកជជែកជុំគ្នាជាពួកជាក្រុម ២-៣នាក់ដែរ ។ នាយកសាលាខ្លះនៅជាសញ្ជាតិបារាំងនៅឡើយ គឺជាសមាជិក "សហប្រតិបត្តិការវប្បធម៌បារាំង នៅកម្ពុជា Cooperation culturelleFrancaise au Cambodge" ថ្វីត្បិតតែកម្ពុជាបានឯករាជ្យពេញលេញហើយក៏ដោយ ។ កម្មវិធីមានខ្មែរ-បារាំង នៅលាយគ្នាតាំងពីថ្នាក់កុមារដ្ឋានតែ៣ឆ្នាំបន្ទាប់មកសិស្សអាចនិយាយនឹងសរសេរភាសាខ្មែរ ឬបារាំងបានយ៉ាងស្ទាត់ជំនាញតែភាសាខ្មែរចេះតែកើនចំនួននឹងកើនគុណភាពចេះតែច្រើនឡើងដែរ ។ លិខិតសរសេរជាផ្លូវការគេនៅឆ្លើយឆ្លងគ្នាចាភាសាបារាំងនៅឡើយ មិនថានៅក្រសួងនៅការិយាល័យសាលារៀន ឬក៏បន្ទាយទាហ៊ាននោះទេ។

ពីមាត់បន្ទួចនៃថ្នាក់កុមារដ្ឋាន"គ"ទៅ គេអាចមើលឃើញចរាចរតាមផ្លូវថ្នល់ដែលជាដីទូលបានយ៉ាងងាយរថយន្តទាហ៊ាននឹងស៊ីវិលបានបរកាត់ទីនោះយ៉ាងច្រើនមែនតែនៅពេលឃើញរថយន្ត"ជេអិនសេ" ឬ"កាត់ៗ" ឬក៏"ហ្សីប"ម្តងៗ ក៏ចេះតែនឹកថា ជារថយន្តនៃបន្ទាយជើងខ្មៅរបស់ឪពុកខ្លួនជាញឹកញយ...ព្រឹកមួយនៃចុងខែកញ្ញា ក៏មានក្បួនរថយន្តយោធាប្រមាណជា ១០គ្រឿង ដឹកគ្រួសារទាហ៊ានយ៉ាងពេញណែនបើកឡើងគគ្រឹកផែនដីបន្តកន្ទុយគ្នាមិនដាក់ ចៅពិននឹកថា ប្រាកដជាក្បួនរថយន្តទាហ៊ាន ConvoieMilitaire ដែលនាំក្រុមគ្រួសារលោកកុម៉ង់ដង់ម៉ាំង សំដៅទៅភ្នំពេញនោះប្រាកដជាមិនខានទេ ដែលធ្វើឱ្យចៅពិនស្រងូតស្រងាត់ក្នុងចិត្តយ៉ាងខ្លាំង ខុសប្រក្រតី អស់មួយព្រឹក ធ្វើឱ្យអ្នកគ្រូម៉ាន់យ៉ុនឆ្ងល់ពីអកប្បកិរិយាចំឡែករបស់ចៅពិន ហើយក៏សួរថា "តើចៅពិន មានការលំបាកក្នុងចិត្តរឿងអ្វីបានជាមិនចូលរួមក្នុងសាលាជាមួយនឹងគេ នៅព្រឹកនេះ?" ចៅពិនតបទៅវិញថា"ឥតមានអីទេ អ្នកគ្រូ!" អ្នកគ្រូក៏បន្តថា "បើឯងមានអីនឹងប្រាប់អ្នកគ្រូចូរឯងលើកដៃ អ្នកគ្រូនឹងមកស្តាប់ឯងដឹងទេ?" ថាហើយក៏ដើរចេញទៅទាំងមិនដឹងថា ចំពោះចៅពិន ឪពុក-ម្តាយរបស់គេបានចាកចេញពីកំពង់ស្ពឺដោយឥតបានលាគ្នាយ៉ាងនេះ ចៅពិនខកចិត្តខ្លាំងណាស់ ។

ពេលចេញទៅហូបបាយថ្ងៃត្រង់នៅម៉ោង ១១ ចៅពិន បានសួរសំនួរទៅបងស្រីរបស់ខ្លួន អ្នងបង ស៊ុននី តបថា "ម៉ាក់បានប្រាប់អ្នកបងពីម្សិលមិញថា ពួកគាត់ត្រូវចេញដំណើរនៅថ្ងៃស្អែកនេះហើយ ដូច្នេះគឺនៅថ្ងៃនេះហើយ..." ចៅពិននិយាយប្រាប់បងថា "ខ្ញុំបានឃើញឡានកុងវ៉ៃរជាច្រើន ពីព្រឹកមិន ចេញកាត់តាមសាលាខ្ញុំ ខ្ញុំដឹងថា ម៉ាក់ប៉ាមុខជានៅក្នុងនោះហើយ!..." អ្នកបងតបថា "អូនឯងពូកែទាយណាស់..." ចៅពិនក៏សប្បាយចិត្តដោយបានទាយត្រូវ អ្នកបងក៏បន្តថា "នៅពេលពួកគាត់រៀបចំផ្ទះសម្បែងរួចស្រួលបួលនៅភ្នំពេញហើយ យើងនឹងនាំគ្នាទៅលេងគាត់នៅឯភ្នំពេញវិញម្តង មែនទេ?" ចៅពិនក៏រីករាយមកវិញ រួចតបថា "មែនហើយ ! យើងនាំគ្នាជិះឡានឈ្នួលទៅភ្នំពេញទៅលេងប៉ាម៉ាក់ មែនទេ!..."ងាកមកសួរក្មួយៗ អាធានឹងអាព្រឿងដែលនៅតូចៗនៅឡើយ គេក៏នាំគ្នាសើច ហើយទះដៃផង...បន្តរហូបបាយនឹងសម្លរនឹងឆាយ៉ាងរីករាយ ។ ម៉ោង១កន្លះ ចៅពិនស្លៀកពាក់យួរកាតាបលឿងរបស់ខ្លួនចេលដំណើរទៅសាលារៀនសាជាថ្មី ស្របពេលនឹងមិត្ត "ពីម៉ឺន" ចេញទៅរៀនដែរ ក៏ដើរទៅជាមួយគ្នាជជែកលួនល្ហឺន មិនដឹងជារឿងអ្វីខ្លះទេ...។

**តទៅលេខក្រោយ**

# ខ្មែរ ប៊ូទិក និងហាងលក់ទំនិញគ្រប់លក្ខណៈសំរាប់លក់

មានទីតាំងនៅកណ្តាលក្រុងខ្មែរឡូវែល

ហាងខ្មែរលក់វត្ថុអនុស្សាវរីយ៏

-ពាណិជ្ជកម្មសម្រាប់លក់ និងរបស់របរទាំងអស់ក្នុងហាង

ទាក់ទងម៉ូនីកា **978 421 6799**

**Khmer Boutique and Gift Shop for Sale**
**Centrally located in the Cambodia Town Lowell**
**Business and inventory for sale**
**Contact Monica 978-421-6799**

# ការិយាល័យ មេធាវី ថំមាស ស្តាលីយ៉ាណូស

**Law Office of Thomas Stylianos Jr.**
**287 Appleton St. Lowell MA 01852**

- Immigration • អន្តោប្រវេសន៏
- Auto Crash • គ្រោះថ្នាក់រថយន្ត
- Divorce • លែងលះប្តីប្រពន្ធ

សូមទាក់ទង សោភា ឬ ធំ **978-459-5000 or 800-308-3766**
**www.thomasinlowell.com**


**KhmerPost USA, LLC**
សារពត៌មានខ្មែរផុសសហរដ្ឋអាមេរិក
អាស័យដ្ឋាន 45 Merrimack St. Suite 218A. Lowell, MA 01852
លេខទូរស័ព្ទ Phone: 978 677-7163 | Fax: (978) 677-7092
អ៊ីម៉ែល info@khmerpost.us
អានកាសែតនៅគេហទំព័រ www.khmerpost.us

ផ្សាយពាណិជ្ជកម្ម **Advertising**
អគ្គនាយក សុបិន្ត ពិន Soben Pin, *Owner/Publisher*
លេខទូរស័ព្ទ 978 - 656 - 8141 (Mobile) 978 677-7163 (Office)
អ៊ីម៉ែលsobenpin@khmerpost.us

អ្នកនិពន្ធ **Editorials**
និពន្ធនាយក ពិន សំខុន Roger Samkhon Pin, *Editor*
(978) 942 - 1641 | rogerpin@khmerpost.us
ការីនិពន្ធ Staff Writers:
អ្នកនិពន្ធកិត្តិយស **Staff Writer/Translator**
Sokharath Koy
ច្នៃសោភ័ណភាពកាសែត **Design Artist**
Heng Chhunleng
ជំនួយការរដ្ឋបាល Office Coordnator
Sochet Chhen


The KhmerPost USA is a free biweekly Cambodian newspaper and serves the Greater Merrimack Valley, Boston, and Rhode Island. It prints mostly in Khmer and provides important news and information to the people who often are isolated from the larger community due to a language barrier. This includes not only national and international news but practical local information concerning health, education, politics, businesses and community involvement. It publishes twice a month from Lowell, Massachusetts.

Mail subscription is available within the U.S. & Canada at $60.00 year.

Follow us: Facebook | Twitter KhmerpostUSA

# MARCOTTE LAW FIRM

## ក្រុមហ៊ុនមេធាវី Marcotte

45 MERRIMACK STREET
LOWELL, MASSACHUSETTS
(978) 458-1229

- សេចក្តីអន្តរាយដល់បុគ្គល
- សំណងបុគ្គល
- ពិការភាពដោយសន្តិសុខសង្គម
- បទព្រហ្មទណ្ឌផ្លូវភេទ និងថ្នាំញៀន
- ច្បាប់គ្រួសារ និងផែនការអចលនទ្រព្យ
- បណ្តឹងវិវាទទូទៅ
- បើកបរនៅពេលស្រវឹង និងប្រព្រឹត្តបទល្មើសពេលធ្វើចរាចរណ៏
- ច្បាប់ធានារ៉ាប់រង
- ការរំលោភបទព្រហ្មទណ្ឌ
- គ្រោះថ្នាក់ចរាចរណ៏
- គ្រោះថ្នាក់នៅការដ្ឋាន
- បំណុលអចលទ្រព្យ

**មានបុគ្គលិកនិយាយភាសាខ្មែរលោកអ្នកអាចហៅទូរស័ព្ទមកក្រុមហ៊ុនយើងខ្ញុំដើម្បីពិគ្រោះ**

**(978) 458-1229**

**www.marcottelawfirm.com**

# ដំណឹងរកបុគ្គលិកចែកផ្សាយ

ខ្មែរផុសស.រ.អា.ត្រូវការរកបុគ្គលិកសម្រាប់ចែកផ្សាយកាសែតនៅក្នុងតំបន់មានឡូវែល - លីន រីវែ - ក្រេងស្តុន រ៉ូដអាយឡិន ។ កាសែតចែក២ដងក្នុង១ខែ ។ បេក្ខជនត្រូវមានប័ណ្ណបើកបរ នឹងធ្លាប់ស្គាល់តំបន់ច្បាស់លាស់ ។ សូមទាក់ទងមកទីស្នាក់ការយើង នៅលេខ **978 - 677 7163** ឬទាក់ទងមក **សូបិន 978-656 8141**

ខ្មែរផុស KhmerPost USA

*Cambodian American Biweekly Newspaper*

Connecting 10,000 Khmer-speaking households per Month with an average of 5 members per household. Free Newspaper copies are available in these cities:

Massachusetts:
- Lowell
- Lynn/Revere

Rhode Island:
- Providence
- Cranston

CELEBRATING 10 YEARS

Contact us for the Advertising Opportunity!

**978-677-7163 | http:/khmerpost.us**

## តមកទំព័រទី ០៥ សម្ភាសន៍ជាមួយព្រះអង្គម្ចាស់ ធម្មិកោ...

"រំលាយគណបក្សសង្គ្រោះជាតិ"ទៅវិញ រូបភាព នោះវាអាចទៅជាយ៉ាងណាទៅវិញ?

**ស៊ីសុវត្ថិ ធម្មិកោះ** ខ្ញុំពិបាកនឹងទាយណាស់ ថាអ្វីនឹងកើតមានឡើងតែខាងសង្គ្រោះជាតិនៅតែប្រកាន់ជំហ៊ររអហឹង្សា គឺមិនជម្រុញឱ្យមានបាតុកម្មអីទេ តែបើប្រជាពលរដ្ឋគេបះបោរឡើង យើងក៏មិនដឹងជាធ្វើអ្វីទប់បានដែរទេ សង្គ្រោះជាតិមិនទាន់បានសម្រេចថានឹងធ្វើអ្វីនៅឡើយទេ, តែដែលយើងអាចធ្វើនោះ គឺមិនទៅបោះឆ្នោត វានឹងធ្វើឱ្យគណបក្សប្រជាជននៅឯកោគ្មានការគាំទ្រពីពលរដ្ឋនឹងពីសហគមន៍អន្តរជាតិនឹងមានការដាក់ទណ្ឌកម្មសេដ្ឋកិច្ចដូចនៅភូមាពីមុន ឬក៏នៅកូរ៉េខាងជើងជាដើម, នៅមានលទ្ធភាពមួយទៀតដែរ យើងនឹងទាមទារឱ្យមានការបោះឆ្នោតសេរីនឹងយុត្តិធមិធានាដោយអន្តរជាតិ ពេលនោះ គឺសង្គ្រោះជាតិនឹងបង្កើតឬគាំទ្រគណបក្សថ្មីមួយដែលឈរលើសម្ព័ន្ធភាពនៃលោកប្រធាន សម រង្ស៊ី -កឹម សុខា ដដែល បើទោះជាលោកទាំង២មិនមែនជាប្រធានបក្សក៏ដោយ...

**ខ្មែរផុសស.រ.អា:** បេសកកម្មព្រះអង្គម្ចាស់មកទីនេះចំពេលគណបក្សកំពុងវិកវរ"ផ្ទៃក្នុង" អាចនឹងបែកផងក៏មិនដឹង, តើព្រះអង្គមានការជាក់ច្បាស់ក្នុងព្រះទ័យទេថា"ព្រះអង្គនឹងបំពេញបេសកកម្ម"ស្របតាមបំណងបក្សរបស់ព្រះអង្គបាន? បើធ្វើបានតើធ្វើយ៉ាងណា?

**ស៊ីសុវត្ថិ ធម្មិកោះ** ខ្ញុំមិនជឿថានឹងបែកទេ! បើនឹងបែកវារលាយទាំងអស់គ្នា...ការវិកវរផ្ទៃក្នុង



ប៉ូលិសចាប់ខ្លួនលោក កឹម សុខា ប្រធានគណបក្សសង្គ្រោះជាតិយប់ថ្ងៃទី ០៣ សីហា

គឺជាវិបត្តិដែលគណបក្សសង្គ្រោះជាតិឥឡូវ មានភាពចាស់ទុំគ្រប់គ្រាន់នឹងដោះស្រាយបានហើយ បើមានជនបង្កប់ ក៏វានឹងបញ្ចប់បាននៅខាងមុខបន្តិចទៀតនេះដែរ... សម្រាប់បេសកកម្មខ្ញុំ បើខ្ញុំមិនប្រើមហិច្ឆិតាខ្លួនឯង មិនប្រើមហិច្ឆិតាបក្សក៏នៅមានមហិច្ឆិតាសម្រាប់ជាតិដែលយើងត្រូវបំរើដែរ អ្នកដែលមកដល់ទីនេះ មានតំណាងរាស្ត្រជាច្រើន(ចេញមកក្រៅ៣ភាគ៤ហើយ) មានលោកប្រធាន សម រង្ស៊ី មានកញ្ញា កឹម វិទ្យា ដែលកំពុងធ្វើការបំរើប្រទេសជាតិដូចខ្ញុំដែរ គឺពន្យល់អ្នកដឹកនាំអាមេរិកាំងពីស្ថានការជាក់ស្តែងដែលកំពុងតែបែរទៅរករបបផ្តាច់ការយើងនាំគ្នាទាមទារឱ្យកម្ពុជាមានលទ្ធិប្រជាធិបតេយ្យឡើងវិញ ឱ្យមានការបោះឆ្នោតត្រឹមត្រូវ... ទាំងនេះថ្នាក់ដឹកនាំយើងធ្វើបានដូចគ្នាទាំងអស់ឬដូច្នេះយើងត្រូវបង្កើនសេចក្តីថ្លែងការបង្កើនសកម្មភាពនៅក្នុងស្រុក ដើម្បីឱ្យអន្តរជាតិគេបានឃើញធ្វើសកម្មភាពឱ្យគេអាចជួយបានផង បើគ្មានសកម្មភាពក្នុងស្រុក គេមិនជួយយើងទេ, អីចឹងខ្ញុំត្រូវតែទៅកម្ពុជាវិញ ដើម្បីដឹកនាំសកម្មភាពសង្គ្រោះជាតិបន្តរកុំឱ្យដាច់...

**ខ្មែរផុសស.រ.អា:** លោកបណ្ឌិត ឡាវ ម៉ុងហៃ បានអត្ថាធិប្បាយម្សិលមិញនេះថា"លោក ហ៊ុន សែន កាន់អំណាចតែម្នាក់ឯងតាមរបបផ្តាច់ការនឹងធ្វើឱ្យរាស្ត្របះបោរ"តើហេតុអ្វីបានជាសង្គ្រោះជាតិ ខ្លាចរាស្ត្របះបោរ?

**ស៊ីសុវត្ថិ ធម្មិកោះ** បើយើងនិយាយពីរាស្ត្របះបោរ ក៏យើងត្រូវដឹងពីវិធីសម្រាប់ទប់ទល់ដែរ, មកទល់ថ្ងៃនេះមិនច្បាស់ថា ការបះបោររបស់ប្រជាជាតិ នឹងទទួលលទ្ធផលជាវិជ្ជមាននៅឡើយទេ សូមមើលប្រទេសអ៊ីរ៉ាក់ប្រទេស អេជីបប្រទេស លីប៊ី ក៏ដូចគ្នា ពុំទាន់បានផលជាវិជ្ជមានទេ ជាទូទៅគឺអ្នកដឹកនាំកម្លាំងបះបោរហ្នឹងហើយជាអ្នកកាន់អំណាចជាអ្នកចំណេញ...

**ខ្មែរផុសស.រ.អា:** ប្រសិនបើការបះបោរនោះទប់មិនជាប់ទេ តើសង្គ្រោះជាតិមានមធ្យោបាយនឹងសង្គ្រោះហើយបញ្ចប់ការបះបោរដោយសន្តិភាពបានទេ? ស៊ីសុវត្ថិ ធម្មិកោ យើងមានលទ្ធភាព ១-ឱ្យអន្តរជាតិគាំទ្រនៅលើមូលដ្ឋាននយោបាយរបស់យើងមួយ ២-យើងចរចារជាមួយអំណាចដែលកាន់កាប់នៅក្នុងស្រុកហ្នឹង នៅលើមូលដ្ឋានដូចគ្នា...ក៏ប៉ុន្តែឱ្យយើងទៅជម្រុញឱ្យមានការបះបោរ គឺឥតមានទេ...

**ខ្មែរផុសស.រ.អា. សូមអរព្រះគុណចំពោះបទសម្ភាសន៍នេះ។**


# បង់ថ្លៃបូកផ្សំ $0

ណាត់ជួបវេជ្ជបណ្ឌិត $0 | ការមើលថែធ្មេញ $0 | សេវាចក្ខុវិញ្ញាណ $0

Senior Whole Health (HMO SNP) គឺជាផែនការសុខភាព Medicare Advantage មួយសម្រាប់ជនជរាអាយុ 65 ឆ្នាំឡើងទៅ ដែលមាន Medicare និង MassHealth Standard។ សមាជិកទទួលបានអត្ថប្រយោជន៍ Medicare និង MassHealth រួមបញ្ចូលទាំងការធានាលើថ្នាំតាមវេជ្ជបញ្ជា Part D បូកផ្សំនឹងអត្ថប្រយោជន៍ច្រើនទៀតដូចជា៖

- ប័ណ្ណ OTC សម្រាប់ទិញថ្នាំ និងផលិតផលិតផលទាក់ទងនឹងសុខភាពជាក់លាក់ដែលមិនចាំបាច់វេជ្ជបញ្ជា *(រហូតដល់ $300 ក្នុងមួយឆ្នាំ ឬ $75 ក្នុងមួយត្រីមាស)*
- អ្នកផ្តល់ជំនួយតាមផ្ទះជួយអ្នកក្នុងរឿងចំណីអាហារ និងការចល័ត
- ការធ្វើដំណើរទៅមកពីកន្លែងណាត់ជួបពិនិត្យសុខភាព
- សមាជិកម្នាក់ៗទទួលបានអ្នកគ្រប់គ្រងសេវាថែទាំគិលានុបដ្ឋាកដែលសម្របសម្រួលការមើលថែទាំរបស់អ្នកដើម្បីឆ្លើយតបនឹងតម្រូវការជាបុគ្គលរបស់អ្នក។

**ទាំងអស់ក្នុងផែនការងាយស្រួលតែមួយពី Senior Whole Health។**



ប្រសិនបើអ្នកមាន MassHealth Standard តែពុំមានការធានា Medicare Part A និង/ឬ Part B ទេ អ្នកអាចនឹងមានសិទ្ធិចុះឈ្មោះក្នុងកម្មវិធី MassHealth Senior Care Options (SCO)។

SWH
SENIOR WHOLE HEALTH®
Simple. Secure. Independent.

សម្រាប់ព័ត៌មានបន្ថែម ហៅទូរស័ព្ទ៖
**1-888-566-3526**
(លេខឥតគិតថ្លៃ) TTY/TDD:711
www.seniorwholehealth.com/SNP
យើងបើកពីម៉ោង 8 ព្រឹកដល់ 8 យប់ 7 ថ្ងៃក្នុងមួយសប្តាហ៍។

*Senior Whole Health គោរពតាមច្បាប់ស្តីពីសិទ្ធិពលរដ្ឋសហព័ន្ធ ដែលគ្រប់ដណ្តប់ និងមិនរើសអើងពូជសាសន៍ ពណ៌សម្បុរ ដើមកំណើត អាយុ ពិការភាព ឬភេទឡើយ។*
*ATENCIÓN: si habla español, tiene a su disposición servicios gratuitos de asistencia lingüística. Llame al 1-888-794-7268 (TTY/TDD: 711).*
*ATENÇÃO: Se fala português, encontram-se disponíveis serviços linguísticos, grátis. Ligue para 1-888-794-7268 (TTY/TDD: 711).*

សុខភាពពេញលេញសម្រាប់មនុស្សចាស់ជរា (HMO SNP) និងសុខភាពពេញលេញសម្រាប់មនុស្សចាស់ជរា NHC (HMO SNP) គឺជាផែនការថែទាំសម្របសម្រួលជាមួយនឹងកិច្ចសន្យាអត្ថប្រយោជន៍ Medicare និងកិច្ចសន្យាជាមួយសហធនម៉ាសាជូសេត/កម្មវិធីសុខភាពសាធារណៈ EOHHS។ ការចុះឈ្មោះធ្វើឡើងតាមការស្ម័គ្រចិត្ត និងអាស្រ័យលើការបន្តកិច្ចសន្យារាល់ឆ្នាំ។ ព័ត៌មាននេះពុំមែនជាការពិពណ៌នាពេញលេញនៃអត្ថប្រយោជន៍ឡើយ។ ទាក់ទងផែនការនេះសម្រាប់ព័ត៌មានបន្ថែម។ អាចនឹងមានការដាក់កម្រិត ការបង់ថ្លៃបូកផ្សំ និងការកំហិត។ អត្ថប្រយោជន៍អាចផ្លាស់ប្តូរនៅថ្ងៃទី 1 ខែមករានៃឆ្នាំនីមួយៗ។ សហាច់ណាយអាចប្រែប្រួលអាស្រ័យលើកម្រិតនៃជំនួយបន្ថែមដែលលោកអ្នកទទួលបាន។ សូមទំនាក់ទំនងទៅផែនការសម្រាប់ព័ត៌មានលម្អិតបន្ថែម។ ផែនការនេះអាចប្រើបានសម្រាប់អ្នកអាយុ 65 ឆ្នាំឡើងទៅ ដែលទទួលជំនួយវេជ្ជសាស្ត្រពីរដ្ឋ និង Medicare។ H2224_2016_138kh Accepted 11/25/2016

# ព្រៃឈើនៅតាម ដងអូរព្រំដែន ស្រស់បំព្រងគាប់ភ្នែក



**ខេត្តប៉ៃលិន :** បើអ្នកទេសចរជិះម៉ូតូតាមផ្លូវក្រវាត់ព្រំដែនចាប់ពីភូមិផ្សារព្រំ ឃុំស្ទឹងកាច់ ស្រុកសាលាក្រៅ ឆ្ពោះទៅទិសខាងត្បូង គេនឹងសង្កេតឃើញព្រៃភ្នំ និងព្រៃដែលដុះនៅតាមមាត់អូរបញ្ចេញពណ៌ខៀវស្រងាត់ គួរឱ្យចង់គយគន់ និងស្រស់ស្រាយក្នុងអារម្មណ៍។

ប្រជាពលរដ្ឋរស់នៅក្បែរព្រំដែន កាលពីពេលថ្មីៗកន្លងមកឱ្យដឹងថា ទេសភាពព្រៃឈើនៅតាមភ្នំ និងជ្រលងដងអូរបញ្ចេញពណ៌ខៀវខ្ចីស្រស់បំព្រងទាក់ទាញភ្នែកភ្ញៀវទេសចរ ដែលនាំគ្នាដើរលេងកម្សាន្តបំបាត់ការអផ្សុក និងភាពធុញថប់ក្នុងអារម្មណ៍ ។ ជាពិសេសកាលពីរដូវភ្ជុំបិណ្ឌកន្លងទៅ ខណៈអ្នកខ្លះទៅលេងទឹកធ្លាក់ភ្នំខៀវ និងរមណីយដ្ឋានផ្សេងៗ ប៉ុន្តែមនុស្សមួយចំនួននាំគ្នាបើកម៉ូតូ និងរថយន្តទៅលេងកម្សាន្តនៅតាមផ្លូវដងអូរក្រវាត់ព្រំដែនយ៉ាងសប្បាយរីករាយ ។ លើសពីនេះផ្លូវព្រំដែនដ៏ធំទូលាយដែលអាជ្ញាធរ បានកសាងកាលពីពេលថ្មីៗកន្លងទៅបង្កលក្ខណៈងាយស្រួលដល់អ្នកដែលរស់នៅតំបន់ព្រៃភ្នំ ព្រមទាំងការធ្វើដំណើរ ។

បើតាមសម្តីរបស់ភ្ញៀវទេសចរនៅក្នុងមូលដ្ឋានឱ្យដឹងថា "ការធ្វើផ្លូវក្រវាត់ព្រំដែនទទួលបានផលចំណេញច្រើន ដោយអាចការពារទឹកដីរបស់យើងឱ្យបានគង់វង្ស ហើយក៏ក្លាយទៅជាកន្លែងធ្វើដំណើរកម្សាន្តទស្សនាទេសភាពព្រៃឈើនៅតាមដងអូរ ដែលមានទឹកហូររេញៗ ធ្វើឱ្យមានអារម្មណ៍ស្រស់ថ្លា និងបង្កើនកម្លាំងចិត្ត កម្លាំងកាយបន្ថែមទៀត" ។

ចំណែកប្រជាពលរដ្ឋរស់នៅក្បែរតំបន់ព្រំដែនបានដាំដំណាំជាច្រើនប្រភេទដូចជាពោតដំឡូងមី ស្វាយ និងតាំងែន ហៅមៀនប៉ៃលិនជាដើម ដែលបានផលដឹកយកទៅលក់នៅក្រុងប៉ៃលិនទាន់ពេលវេលា ព្រោះមានផ្លូវក្រាលក្រួសក្រហមដ៏ល្អ ។ លើសពីនេះក៏មានប្រជាពលរដ្ឋដាំដំណាំបន្លែអន្លក់ក្បែរមាត់អូរ ដោយមានទឹកខ្ទបប្រាំងខ្ទបវស្សាបូមយកទៅស្រោចហើយទទួលផលលក់បានប្រាក់ផ្គត់ផ្គង់ជីវភាពគ្រួសារ ៕









# REACH THOUSANDS OF PEOPLE IN THE CAMBODIAN COMMUNITY

## WITH COST EFFECTIVE NEWSPAPER ADVERTISING

KhmerPost USA

### DISTRIBUTION

*70+ Locations in Lowell, MA*
*7,000 copies per month*

*25 Locations in Lynn & Revere, MA*
*1,000 copies per month*

*25 Locations in Providence & Cranston, RI*
*2,000 copies per month*

Lowell

Lynn

Revere

Providence

Cranston

### PUBLISHING

*Two Issues Every Month*

### READERSHIP

*50,000 Monthly*
*600,000 Annually*

***Khmer Post USA Distribution Locations Include:***

- *Households*
- *Markets*
- *Retail Businesses*
- *Restaurants*
- *Office Buildings*
- *Government Offices*
- *Chamber of Commerce*
- *Buddhist Temples*
- *Laundromats*
- *And Much More*

| 2017 PRINTING DATES | 2018 PRINTING DATES |
|---|---|
| July 10 & 24 | January 5 & 19 |
| August 7 & 21 | February 5 & 19 |
| September 11 & 25 | March 5 & 19 |
| October 9 & 23 | April 6 & 20 |
| November 6 & 20 | May 7 & 21 |
| December 4 & 18 | June 8 & 2 |

***Advertising deadlines are 5 business days prior to printing date.***

### ADVERTISING RATES AND SIZES

*All ads are printed in Full Color*

| Ad Size (WxH) | 1 Issue | 3 Months (6 Issues) 5% Savings | 6 Months (12 Issues) 7.5% Savings | 12 Months (24 Issues) 10% Savings |
|---|---|---|---|---|
| **Full** (10" x 13") | $460 | $2,622 | $5,106 | $9,936 |
| **1/2** (10" x 6.5") | 310 | 1,674 | 3,441 | 6,696 |
| **1/4** (5" x 6.5") | 165 | 940 | 1831 | 3,564 |
| **1/8** (5" x 3.25") | 90 | 513 | 999 | 1,944 |

### CONTACT INFO

**45 Merrimack Street • Suite 218A • Lowell, MA 01852**
**Tel: 978.677.7163 • Fax: 978.677.7092 • Email: sobenpin@khmerpost.us**
**www.khmerpost.us**

CELEBRATING 10 YEARS

*Khmer Post USA is a proud member of the Greater Lowell Chamber and Greater Merrimack Valley Convention and Visitors Bureau*

# ជំងឺលើសសម្ពាធឈាម និងទឹកនោមផ្អែម ខ្លាចបន្លែ៣មុខនេះណាស់







ប្រសិនជាអ្នកចង់គ្រប់គ្រងសម្ពាធឈាម និងជាតិស្ករក្នុងខ្លួនអ្នកមិនឱ្យឡើង អ្នកអាចជ្រើសរើសបន្លែទាំង៣ប្រភេទនេះដើម្បីពិសារបាន ។

**តើមានអ្វីខ្លះទៅ?**

**១ ត្រឡាច**

វាជាបន្លែដែលអាចជួយទប់មិនឱ្យសម្ពាធឈាម និងជាតិស្ករក្នុងខ្លួនអ្នកឡើងខ្ពស់ឡើយ ។ ជាពិសេស វាថែមទាំងអាចជួយការពារអ្នកមិនឱ្យងាយចាស់ស្បែកនឹងភ្លឺ ហើយម៉ត់រលោងជាមិនខាន ។

**២ ការ៉ុត**

ក៏ជាបន្លែដែលអាចជួយការពារអ្នកពីជំងឺទាំង២ប្រភេទខាងលើដែរ ។ មិនត្រឹមតែប៉ុណ្ណោះ វានឹងជួយធ្វើឱ្យភ្នែកអ្នកភ្លឺ ថែមទាំងជួយឱ្យធ្មេញ និងពោះវៀនមានសុខភាពល្អទៀតផង ។ ជាពិសេស វាក៏អាចជួយបង្កើនប្រព័ន្ធការពាររាងកាយរបស់អ្នកឱ្យរឹងមាំផងដែរ ។

**៣ ផ្កាខាត់ណា**

ជាបន្លែដែលសម្បូរវីតាមីនសេ ដែលអាចជួយធ្មេញអ្នកឱ្យបញ្ចេញជាតិពុលចេញមកក្រៅអស់ ។ វាមិនត្រឹមតែអាចការពារអ្នកពីជំងឺលើសសម្ពាធឈាម និងជំងឺទឹកនោមផ្អែមទេ ថែមទាំងអាចជួយការពារអ្នកឱ្យចៀសពីជំងឺបេះដូងទៀតផង ។ ជាពិសេសអ្នកនឹងមិនងាយប្រឈមមុខនឹងជំងឺមហារីកនោះទេ ៕


*For your special day...*

*សម្រាប់ថ្ងៃដ៏ពិសេសរបស់អ្នក*



**The UMass Lowell Inn & Conference Center** provides timeless, modern elegance with a relaxing atmosphere.

You and up to 450 guests will be catered to by our attentive staff, while you celebrate in style and comfort.

We offer overnight lodging, scenic outdoor photo opportunities, and a variety of ceremony spaces, including smaller rooms for showers, rehearsal dinners, and engagement parties.

All of our menus can be personalized to suit your individual needs.

UMASS LOWELL
Inn & Conference Center

សណ្ឋាគារ យូម៉ាសឡូវែលនឹងមណ្ឌលប្រជុំ

ផ្តល់ជូនយ៉ាងទាន់ចិត្ត ជឿនលឿន សង្ហា ជាមួយនឹងបរិយាកាសយ៉ាងរំភើយ

លោកអ្នកនឹងភ្ញៀវរហូតដល់៤៥០នាក់អាចនឹងជប់លៀង ដោយមានការយកចិត្តទុកដាក់ពីបុគ្គលិកយើង នៅពេលដែលលោកអ្នកកំពុងរៀបពិធី ប្រកបដោយសម្បូរបែបនឹងយ៉ាងកក់ក្តៅ ។

យើងផ្តល់ជូនការស្នាក់អាស្រ័យឆ្លងរាត្រី, ទីធ្លាខាងក្រៅគួរឲ្យរំភើបសម្រាប់ មានឱកាសថតរូបនឹងបន្ទប់សម្រាប់ពិធីការគ្រប់ធុន,

រាប់ទាំង បន្ទប់តូច សម្រាប់បង្កក់កូន, ត្រៀមសម្រាប់ជប់លាងអាហារពេលល្ងាចនឹងពិធី ភ្ជាប់ពាក្យ...។
គ្រប់បញ្ជីមុខម្ហូបអាចនឹងរៀបចំជូនស្របតាមតម្រូវការរបស់បុគ្គលម្នាក់ៗបាន ។

**UMass Lowell Inn & Conference Center**
50 Warren St., Lowell MA 01852 978-934-6920 877-886-5422 **www.uml.edu/icc**


CITY OF
LIGHTS
11–25–17
12 - 4pm Hot Chocolate Competition
Downtown Lowell
4.30 to 6.30pm Holiday Parade Parade
Starts at Jackson Street,
Ends in front of City Hall
2 - 4.30 pm Sing Alongs - JFK Plaza
2 to 5pm Pony Rides - JFK Plaza
2 - 5pm Santa Pictures - JFK Plaza
1 & 2pm Magic Show
2pm Movie @ LNHP Visitor Center
1 - 7pm Vintage Holiday Market (Fr. 5-9pm)
Lucy Larcom Park
12 - 5pm Festival of Wreaths
Mason Temple
10 to 2pm Children's Shopping
Pollard Library
and more...
See webpage for more info!
LOWELLCITYOFLIGHTS.ORG
Festivities start at 12pm
ម៉ោង ១២ថ្ងៃត្រង់ - ៤ ល្ងាច ការប្រគួតផឹកសុខកូឡាក្តៅ
នៅ ដោនថោន ឡូវែល
ម៉ោង ៤:៣០ រសៀល - ៦:៣០ ល្ងាច ការដើរព្យុហយាត្រា
ដោយចាប់ផ្តើមពីចំណុចផ្លូវ Jackson Street បញ្ចប់នៅមុខសាលាក្រុង
ម៉ោង ២ រសៀល -៤:៣០ ល្ងាច កម្មវិធីច្រៀងកំសាន្តជាមួយភ្លេង - នៅ JFK Plaza
ម៉ោង ២ រសៀល -៥ ល្ងាចជិះសេះកំសាន្ត(Pony Rides) - នៅ JFK Plaza
ម៉ោង ២ រសៀល - ៥ ល្ងាចរូបថតសាន់តា ខ្លូស - នៅ JFK Plaza
ម៉ោង ១ រសៀល -២រសៀល កម្មវិធីសម្តែងសៀក
ម៉ោង ២រសៀល បញ្ចាំងភាពយន្ត នៅមជ្ឈមណ្ឌល LNHP Visitor Center
ម៉ោង ១ រសៀល -៧យប់ Vintage Holiday Market ( ថ្ងៃសុក្រ ម៉ោង ៥ រសៀល -៩យប់)
នៅសួន Lucy Loarcom Park
ម៉ោង ១២ ថ្ងៃត្រង់-៥ល្ងាច កម្មវិធី Festival of Wreaths
នៅ Mason Temple
ម៉ោង ១០ព្រឹក-២រសៀល កម្មវិធីដើរទិញអីវ៉ាន់របស់ក្មេងៗ
នៅ Pollard Library
និងមានកម្មវិធីជាច្រើនទៀត
សូមចូលទៅកាន់គេហទំព័រសម្រាប់ព័ត៌មានបន្ថែម
LOWELLCITYOFLIGHTS.ORG
កម្មវិធីនេះចាប់ផ្តើមចាប់ពីម៉ោង ១២ ថ្ងៃត្រង់
#LOWELL
THERE'S A LOT TO like.
Greater Merrimack Valley
Convention & Visitors Bureau
adventuresawait
GREATER LOWELL
CHAMBER OF COMMERCE
ថ្ងៃអាទិត្យ ទី២៥ ខែវិច្ឆិកា ឆ្នាំ ២០១៧ ● LIKELOWELL.COM